00615556

លេខ/No: D427/3/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ-១៤៦)

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្ដីលោក នួន ជា

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 20 / 10 / 2010
ម៉ោង (Time/Heure): 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ** / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ**

---

<u>ដាក់ដោយ៖</u>

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ
Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
ព្រំ ផល្លា
Annebrecht VOSSENBERG (កម្មសិក្សាការីច្បាប់)

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៦៧ វិធាន ៧៤ និងវិធាន ៧៥ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) សហមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា (“ក្រុមមេធាវីការពារក្តី”) សូមដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[1] របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) ជូនអង្គបុរេជំនុំជម្រះ (“អ.ប.ជ”)។ ដូចមានហេតុផលលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា៖ (i) បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន និង (ii) សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) មានការភ័ន្តច្រឡំនៅលើអង្គច្បាប់នៅពេលបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក លើបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ (ដែលចាប់ពីពេលនេះទៅហៅថា “ឧក្រិដ្ឋកម្មសង្គ្រាម”) និងទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀត ដូចមានចែងនៅក្នុងដីកាដំណោះស្រាយ។

## II. អង្គហេតុពាក់ព័ន្ធ

២. ទាក់ទងនឹងយុត្តាធិការរបស់ អ.វ.ត.ក ក.ស.ច.ស បានសម្រេចថា “បទល្មើស ក៏ដូចជាទម្រង់នៃការទទួលខុសត្រូវ ដូចបានកំណត់នៅក្នុងផ្នែកនេះនៃដីកាដំណោះស្រាយ [ដែលបានចែងអំពីច្បាប់ជាធរមាន] ស្របទៅនឹងគោលការណ៍នីត្យានុកូលភាព”[2]។ ស.ច.ស បានសម្រេចបន្ថែមទៀតថា បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម និង “ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ[ទាំងអស់] ដែលមានរៀបរាប់នៅក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក សុទ្ធតែត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ដែលអនុវត្តនៅកម្ពុជាក្នុងពេលដែលអង្គហេតុបានកើតឡើង”[3]។

---

[1] ឯកសារ លេខ D-427 ‘ដីកាដំណោះស្រាយ’ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០, ERN 00604508–00605246។

[2] ដីកាដំណោះស្រាយ កថាខណ្ឌ ១២៩៩។

[3] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៨។ សូមមើលផងដែរ ជើងទំព័រខាងលើ កថាខណ្ឌ 1310, 1313, 1316។ កត់សម្គាល់៖ ទម្រង់នៃការទទួលខុសត្រូវដែលបានទាញយោងពីមាត្រា ២៩(ថ្មី) គឺ៖ ការធ្វើផែនការ ការញុះញង់ ការបញ្ជា

៣. នៅពេលធ្វើសេចក្ដីសន្និដ្ឋានដូច្នេះ ក.ស.ច.ស បានសម្រេចថា៖

ក. "[បញ្ហា] ដែលថាតើ អ.វ.ត.ក ជាស្ថាប័នយុត្តាធិការជាតិ ឬ អន្តរជាតិ មិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលើបទល្មើស [...] ដរាបណាគោលការណ៍ *មិនមានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង* ត្រូវបានគោរព"[4]។

ខ. "[ដើម្បី] អាចឱ្យអំពើមួយត្រូវចាត់ចូលជាបទល្មើសនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិក្នុងពេលដែលអំពើនោះបានកើតឡើងនោះទេ នោះច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ត្រូវចែងអំពីបទល្មើសនៃអំពើនោះដោយច្បាស់លាស់ ឬ ដោយតុណ្ហីភាព ហើយអំពើនោះក៏ត្រូវជាបទល្មើសនៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិ ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា នៅខណៈពេលដែលអំពើនោះបានកើតឡើងផងដែរ"[5]។

គ. "ដោយយោងទៅលើ [បទប្បញ្ញត្តិនៃច្បាប់ អ.វ.ត.ក ដែលចែងអំពីយុត្តាធិការលើកម្មវត្ថុនៃរឿងក្ដី] បញ្ហាដែលចោទឡើងថាតើច្បាប់អន្តរជាតិអាច ឬមិនអាចអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជានឹងមិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក នោះឡើយ"[6]។

---

ការជួយ និងជំរុញ ការប្រព្រឹត្តិ និងការទទួលខុសត្រូវរបស់ថ្នាក់លើ/អ្នកបញ្ជា។ អបជ បានសម្រេចពីលើកមុនថា ទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធនៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ('JCE') គឺជាទម្រង់នៃការប្រព្រឹត្តិស្ថិតក្នុងយុត្តាធិការរបស់ *អ.វ.ត.ក*។ សូមមើលឯកសារ លេខ D-97/14/15, 'សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)' ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ERN 00486521–00486589 ('សាលដីកាស្ដីពី JCE')។ ទោះបីជាយ៉ាងណាក៏ដោយ ដីកាដំណោះស្រាយ យោងតែទៅលើទម្រង់មូលដ្ឋាននៃ JCE ប៉ុណ្ណោះ។ សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤១។

[4] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០១។

[5] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០២។

[6] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៤។

ឃ. បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម ព្រមទាំងភាពអនុវត្តទៅបាននៃការទទួលខុសត្រូវទាំងអស់ ដូចមានចែងនៅក្នុងដីកាដំណោះស្រាយ "ត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ ដែលអាចឱ្យជនជាប់ចោទទទួលបានព័ត៌មាន"[7]។

ង. "គោលការណ៍ *មិនមានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង* មិនរារាំងដល់សហចៅក្រមស៊ើបអង្កេតក្នុងការបកស្រាយបទប្បញ្ញត្តិ ដែលទាក់ទងនឹងសមត្ថកិច្ចយុត្តាធិការរបស់ខ្លួនឡើយ ហើយប្រសិនបើចាំបាច់អាចយោងទៅដល់យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀត"[8]។

៤. ផ្អែកលើមូលដ្ឋានទាំងនេះ និងមូលដ្ឋាន (ដទៃទៀត) នួន ជា ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះពីការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្ម

---

[7] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៥ ('បទបញ្ញត្តិនៃច្បាប់អន្តរជាតិដែលហាមប្រាមបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដែលបានកំណត់យ៉ាងច្បាស់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ មានអនុភាពគតិយុត្តិចាប់បង្ខំតម្រូវឱ្យប្រទេសកម្ពុជាត្រូវតែគោរពតាម ដូចមានបកស្រាយខាងក្រោមនេះ ដូច្នេះ បទបញ្ញត្តិទាំងនេះត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដែលអាចឱ្យជនត្រូវចោទទទួលបានព័ត៌មាន ក្នុងឋានៈដែលខ្លួនជាសមាជិកនៃថ្នាក់ដឹកនាំកម្ពុជា')។ ដូចដើងទំព័រខាងលើ កថាខណ្ឌ ១៣០៦ ('ចំពោះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ ការហាមប្រាមបទល្មើសនេះដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ តាមរយៈការជំនុំជម្រះនានាដែលបានធ្វើឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរនៅក្នុងទីក្រុងណួរ៉េមប៊ើក និងតូក្យូ ជាដើម')។ ដូចដើងទំព័រខាងលើ កថាខណ្ឌ ១៣០៧ ('ក្នុង ចំណោមទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងច្បាប់ស្តីពី អ.វ.ត.ក ក៏មានទម្រង់នៃការទទួលខុសត្រូវមួយចំនួនត្រូវបានទទួលស្គាល់ផងដែរនៅក្នុងព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដូចមានបញ្ជាក់ខាងក្រោមនេះ។ ហេតុដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះ ត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ។ ហើយចំពោះទម្រង់នៃការទទួលខុសត្រូវដែលនៅសេសសល់វិញ ដូចជា សហឧក្រិដ្ឋកម្មរួម (JCE) ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ ក៏ត្រូវបានចែងផងដែរដោយច្បាប់អន្តរជាតិ តាមរយៈប្រភពផ្សេងៗ ដូចជា ការជំនុំ ជម្រះនានាដែលត្រូវបានរៀបចំឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំង នេះ ត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ') ។

[8] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៨។

ប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម តាមរយៈទម្រង់នៃការទទួលខុសត្រូវដោយឡែកៗពីគ្នា ចំនួន ៦[9]។

## III. អង្គច្បាប់ពាក់ព័ន្ធ

### ក. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៥. អង្គបុរេជំនុំជម្រះបានបញ្ជាក់នាពេលថ្មីៗនេះថា "ប្រសិនបើដីកាដំណោះស្រាយបញ្ជាក់យុត្តាធិការរបស់ អ.វ.ត.ក" ជនជាប់ចោទ "អាចពិចារណាអំពីអានុភាពវិធាន ៦៧(៥) និងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង នៅពេលអានវិធានទាំងពីរនេះរួមគ្នា"[10]។ វិធាន ៦៧(៥)នៃវិធានផ្ទៃក្នុង ចែងថា ដីកាដំណោះស្រាយ "បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ ដូចមានចែងនៅក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង" ហើយវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យជនជាប់ចោទប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស "ដែលបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក"។ អនុលោមតាមវិធាន ៧៥ នៃវិធានផ្ទៃក្នុង "ដើមបណ្តឹងឧទ្ធរណ៍ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបាននូវការជូនដំណឹងអំពីដីកាសម្រេច [...]"[11] និង "សារណាបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបាននូវការជូនដំណឹងអំពីដីកាសម្រេច [...]"[12]។

### ខ. យុត្តាធិការរបស់ អ.វ.ត.ក

---

[9] សូមមើលដីកាដំណោះស្រាយ កថាខណ្ឌ១៥២១ *et seq*, ១៦១៣។

[10] ឯកសារ លេខ D-345/5/11 សាធារណៈ 'សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ' ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០, ERN 00528364–00528370 កថាខណ្ឌ ១១។

[11] វិធាន ៧៥(១)។

[12] វិធាន ៧៥(៣)។

៦. អនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ច្បាប់ អ.វ.ត.ក")[១៣] "អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងនៅក្នុង*រចនាសម្ព័ន្ធតុលាការដែលមានស្រាប់* [...] ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ [("កម្ពុជាប្រជាធិបតេយ្យ")] និងជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះ [...] ការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា [...] ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងអនុសញ្ញា អន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងពីថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ៦ មករា ១៩៧៩"[១៤]។ សាលាក្តីនេះ "មានអំណាចវិនិច្ឆ័យទោសជនសង្ស័យ ដែលបានប្រព្រឹត្ត *ក្នុងចំណោមបទល្មើសទាំងឡាយនោះ* គឺ (i) បទល្មើសទាំងឡាយដូចមាន ចែងនៅក្នុងក្រមព្រហ្មទណ្ឌ[កម្ពុជា]ឆ្នាំ១៩៥៦"[១៥] "បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមាន ចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍"[១៦] (iii) "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[១៧] (iv) "ការបំពារបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៩"[១៨]។

៧. អនុលោមតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ("រាជរដ្ឋាភិបាលកម្ពុជា") និងអង្គការសហប្រជាជាតិ ("កិច្ចព្រមព្រៀង អ.វ.ត.ក")[១៩] "អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើ

---

[13] ជាផ្លូវការ 'ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

[14] សេចក្តីបញ្ជាក់បន្ថែម។

[15] ច្បាប់ស្តីពី អ.វ.ត.ក មាត្រា ៣។

[16] ច្បាប់ស្តីពី អ.វ.ត.ក មាត្រា ៤។

[17] ច្បាប់ស្តីពី អ.វ.ត.ក មាត្រា ៥។

[18] ច្បាប់ស្តីពី អ.វ.ត.ក មាត្រា ៦។

[19] ជាផ្លូវការ 'កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ' ដែលប្រកាសឱ្យប្រើនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤។

រឿងក្តី ដូចដែលបានចែងក្នុង [ច្បាប់ អ.វ.ត.ក] ដែលបានអនុម័ត និងធ្វើវិសោធនកម្ម ដោយអង្គនីតិបញ្ញត្តិកម្ពុជា នៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជា"[២០]។ ជាពិសេស "យុត្តាធិការលើរឿងក្តីរបស់ [អ.វ.ត.ក] រួមមាន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចដែលបានកំណត់ក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិឆ្នាំ១៩៩៨ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩"[២១]។

៨. អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") បានសម្រេចនាពេលថ្មីៗនេះដូចតទៅ៖ "យុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក កំណត់ត្រឹមតែបទឧក្រិដ្ឋទាំងឡាយណា ដែលមានចែងនៅក្នុងមាត្រា៣ ថ្មី ដល់ មាត្រា ៨ នៃច្បាប់ អ.វ.ត.ក *នៅពេលដែលបទល្មើសដែលបានកំណត់នោះបង្កើតជាបទល្មើស នៅក្នុងអំឡុងពេលនៃការប្រព្រឹត្ត ដែលបានចោទប្រកាន់តែប៉ុណ្ណោះ* [...]"[២២]។

### គ. ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាក្នុងអំឡុងពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩

៩. រដ្ឋធម្មនុញ្ញដែលនៅជាធរមាននៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលដែលពាក់ព័ន្ធរួមមាន៖ (i) រដ្ឋធម្មនុញ្ញនៃរបបសាធារណៈរដ្ឋខ្មែរឆ្នាំ១៩៧២ (ចាប់ពីខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៦) និង (ii) រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦ (ចាប់ពីខែមករា ឆ្នាំ១៩៧៦ ដល់ ខែមករា ឆ្នាំ១៩៧៩)[២៣]។ រដ្ឋធម្មនុញ្ញនីមួយៗមិនបានចែងអនុញ្ញាតឱ្យយក

---

[20] កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក មាត្រា ២(១)។ សូមមើលផងដែរជើងទំព័រខាងលើ មាត្រា ២(២) ('កិច្ចព្រមព្រៀងនេះត្រូវអនុវត្តក្នុងប្រទេសកម្ពុជា តាមរយៈ [ច្បាប់ស្តីពី អ.វ.ត.ក] នៅពេលអនុម័ត និងធ្វើវិសោធនកម្មរួច') ។

[21] កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក មាត្រា ៩។

[22] សំណុំរឿង លេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ ឯកសារ លេខ E-188 'សាលក្រម' ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ERN 00572517–00572797 ('សាលក្រម ឌុច') កថាខណ្ឌ ១៦។

[23] សូមមើល សាលក្រម ឌុច កថាខណ្ឌ ២៩។

ច្បាប់ព្រហ្មទណ្ឌអន្តរជាតិមកអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជាឡើយ[24]។ តាមពិតទៅ លិខិតុបករណ៍នីមួយៗមិនមានបទប្បញ្ញត្តិចែងអំពីអានុភាពនៃច្បាប់អន្តរជាតិលើច្បាប់ជាតិឡើយ[25] ហើយក៏មិនមានយុត្តិសាស្ត្រលើកឡើងលើបញ្ហានេះដែរ[26]។ ហេតុដូច្នេះ ច្បាប់ធម្មនុញ្ញជាតិជាធរមាន មិនអនុញ្ញាតឱ្យយកច្បាប់ព្រហ្មទណ្ឌអន្តរជាតិមកអនុវត្តដោយផ្ទាល់ឡើយ មិនថាច្បាប់ព្រហ្មទណ្ឌកម្ពុជានេះផ្អែកលើមូលដ្ឋាននៃទំនៀមទម្លាប់ ឬសន្ធិសញ្ញាឡើយ[27]។

## ឃ. ច្បាប់ព្រហ្មទណ្ឌកម្ពុជាក្នុងអំឡុងពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩

---

[24] សូមមើល Raoul Jennar, *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៣–១៩៩៣* (White Lotus ឆ្នាំ១៩៩៥)។ កត់សម្គាល់៖ ឃ្លា 'ការអនុវត្តផ្ទាល់នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ' ត្រូវបានគេយល់ថា សំដៅទៅលើការអនុវត្តវិធាននៃច្បាប់អន្តរជាតិជា មូលដ្ឋានសម្រាប់ការកំណត់អំពីឧក្រិដ្ឋភាពនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌក្រោមច្បាប់ជាតិ នៅពេលដែលវិធាននៃច្បាប់អន្តរជាតិនោះ មិនត្រូវបានទទួលស្គាល់ ឬមិនត្រូវបានប្រែក្លាយទៅជាច្បាប់ព្រហ្មទណ្ឌក្នុងស្រុក។ បន្ទាប់មកពាក្យ 'ដោយផ្ទាល់' សំដៅទៅលើអង្គហេតុដែលវាមិនផ្អែកទៅលើជំហានផ្នែកនីតិបញ្ញត្តិដែលចូលមកជ្រៀតជ្រែក។ ការអនុវត្ត ផ្ទាល់នៃច្បាប់អន្តរជាតិ ទាក់ទិននឹងឧក្រិដ្ឋកម្មអន្តរជាតិ មិនមែនមានន័យថា វាត្រូវបានយកមកអនុវត្តដោយមិនគិតអំពីច្បាប់ជាតិឡើយ។ ការអនុវត្តនូវរាល់វិធានទាំងអស់នៃច្បាប់អន្តរជាតិចាំបាច់ត្រូវផ្អែកទៅលើវិធាននៃច្បាប់រដ្ឋធម្មនុញ្ញជាតិ មិនថាចែងជាលាយលក្ខណ៍អក្សរ ឬមិនជាលាយលក្ខណ៍អក្សរឡើយ ដែលគ្រប់គ្រងទៅលើឋានៈនៃច្បាប់នោះនៅក្នុងប្រព័ន្ធច្បាប់ជាតិ។ 'ការអនុវត្តផ្ទាល់' មានន័យយ៉ាងដូចម្ដេចនោះ គឺថា ការអនុវត្ត (តាមរយៈតុលាការ ឬស្ថាប័ននីតិប្រតិបត្តិ) វិធាននៃច្បាប់អន្តរជាតិ គឺមិនផ្អែកទៅលើការតាក់តែងច្បាប់ក្រោយៗមកទៀត ដែលធ្វើឱ្យវិធានពិសេសនោះជាផ្នែកនៃច្បាប់ជាតិនោះឡើយ។

[25] សូមមើល Jennar *ដូចឯកសារយោង២៤ខាងលើ*។

[26] កត់សម្គាល់៖ ការស្រាវជ្រាវដោយយកចិត្តទុកដាក់ មិនបានបង្ហាញនូវយុត្តិសាស្ត្រណាមួយឡើយទាក់ទិននឹងរយៈកាលដែលពាក់ព័ន្ធ ទោះបីជាមិនមានបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញក៏ដោយ ដែលផ្ដល់ជាយោបល់ថា ច្បាប់អន្តរជាតិមានអនុភាពផ្ទាល់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។

[27] សូមមើល Pieter van Dijk, Fried van Hoof, Arjen van Rijn, & Leo Zwaak, THEORY AND PRACTICE OF THE EUROPEAN CONVENTION ON HUMAN RIGHTS, 4th Ed (Intersentia 2006) ទំព័រ 660 ('អនុភាពនៃច្បាប់អន្តរជាតិនៅក្នុងប្រព័ន្ធច្បាប់ជាតិ ត្រូវបានកំណត់ដោយច្បាប់រដ្ឋធម្មនុញ្ញជាតិ។ នៅក្នុងរដ្ឋផ្ដល់សច្ចាប័នទាំងនោះ ដែលច្បាប់អន្តរជាតិមិនមានអនុភាពផ្ទៃក្នុង អនុភាពនេះមិនអាចត្រូវបានផ្ដល់ ក្នុងករណីចែងឡ ទៅឱ្យបទបញ្ញត្តិច្បាប់ព្រហ្មទណ្ឌអន្តរជាតិឡើយ')។

១០. ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺជាច្បាប់ព្រហ្មទណ្ឌជាធរមាននៅក្នុងប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[២៨]។ ក្រមនេះបានចែងយ៉ាងច្បាស់អំពីបទល្មើសទាំងឡាយ ដូចមានចែងនៅក្នុងមាត្រា ៣ នៃច្បាប់ អ.វ.ត.ក (បទមនុស្សឃាត បទទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា)។ ប៉ុន្តែ បទល្មើសទាំងឡាយ ដែលបានយោងចាប់ពីមាត្រា ៤ ដល់ មាត្រា ៦ នៃច្បាប់ អ.វ.ត.ក (បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម) មិនមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឬអត្ថបទច្បាប់ក្នុងស្រុកណាមួយដែលនៅជាធរមានចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ឡើយ។ និយាយឱ្យងាយទៅ បទល្មើសអន្តរជាតិទាំងនេះមិនមែនផ្នែកមួយនៃច្បាប់កម្ពុជានៅក្នុងពេលនៃការកើតឡើងនូវហេតុការណ៍ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយឡើយ។ ទោះបីជាប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ និងអនុសញ្ញាទីក្រុងហ្សឺណែវរួចហើយក៏ដោយ[២៩] មិនដែលមានរដ្ឋាភិបាលកម្ពុជាណាមួយបានអនុម័តច្បាប់ ជាតិនៅមុនពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានកំណត់ទង្វើដូចមានចែងនៅ ក្នុងលិខិតុបករណ៍អន្តរជាតិទាំងនេះថាជាបទល្មើសព្រហ្មទណ្ឌឡើយ។

### ខ. ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអំឡុងពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩

១១. ដើម្បីជាគោលបំណងនៃបណ្តឹងឧទ្ធរណ៍នេះ ក្រុមមេធាវីការពារក្តីសន្និដ្ឋានថា (ដោយមិនឱ្យប៉ះពាល់លើសិទ្ធិរបស់ខ្លួនក្នុងការដាក់សារណាបន្ថែមលើបញ្ហានេះនៅមុនពេល ឬ នៅពេលបើកសវនាការបឋម) បទល្មើសដែលបានយោងចាប់ពីមាត្រា ៤ ដល់ មាត្រា ៦ នៃច្បាប់ អ.វ.ត.ក (បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម) *នៅក្នុងទម្រង់មួយចំនួន* គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះជាសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនានាបានសម្រេច ដោយស៊ីសង្វាក់

---

[28] សូមមើល សាលក្រម ឌុច កថាខណ្ឌ ២៩។

[29]សូមមើលដីកាដំណោះស្រាយ លេខយោង៥១៥៤។

គ្នាថា បទប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មសង្គ្រាម គឺជាផ្នែកមួយនៃ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ ឋានៈនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានលក្ខណៈមិនសូវច្បាស់ឡើយ។ នៅចុងឆ្នាំ១៩៩៤ ចៅក្រម Meron បានកត់សម្គាល់ថា វាមានការលំបាកក្នុងការរកជំហរឱ្យស្របគ្នាមួយថាតើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្ស និងជម្លោះប្រដាប់អាវុធ នៅមានចំណងនឹងគ្នាដែរឬទេ[៣០]។ នៅក្នុងឆ្នាំបន្ទាប់តែប៉ុណ្ណោះទើបអង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY បានប្រកាសថា ចំណងនេះបានកាត់ផ្តាច់រួចទៅហើយ[៣១]។

## ច. គោលការណ៍នីត្យានុកូលភាព

### *១. ក្របខណ្ឌទូទៅ*

១២. គោលការណ៍នីត្យានុកូលភាពគឺជាគោលការណ៍ចំបងមួយនៃច្បាប់ព្រហ្មទណ្ឌ ដែលទាមទារឱ្យគេអាចប្រមើលមើលឃើញ បញ្ជាក់ឱ្យច្បាស់ និងមិនអនុវត្តការហាមឃាត់លើបទព្រហ្មទណ្ឌដោយអានុភាពប្រតិសកម្ម។ ដូចនឹងឃ្លានៃភាសាឡាតាំថា *គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង* ("គ្មានច្បាប់គឺគ្មានបទល្មើស") គោលការណ៍នេះចែងថា ទង្វើមួយមិនអាចជាបទល្មើសឡើយ ទាល់តែ និងលើកលែងតែ ទង្វើមួយនេះត្រូវបានគេប្រកាសយ៉ាងច្បាស់ថាជាបទល្មើស *នៅក្នុងប្រព័ន្ធច្បាប់ពាក់ព័ន្ធណាមួយ*[៣២]។ និយាយឱ្យខ្លីមក គោលការណ៍នេះគឺជាការហាម

---

[30] សូមមើល Theodor Meron, 'War Crimes in Yugoslavia and the Development of International Law', 88 American Journal of International Law 78, 85 (1994)។

[31] សូមមើល រដ្ឋអាជ្ញា ទល់នឹង *Tadic* សំណុំរឿង លេខ IT-94-1-A, 'សេចក្តីសម្រេចលើបណ្តឹងបន្ទាន់បង្ខំរបស់មេធាវីការពារក្តី ទាក់ទងនឹងយុត្តាធិការ' ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ១៤១។

[32] កត់សម្គាល់៖ តាមលក្ខណៈរបស់វា គោលការណ៍នីត្យានុកូលភាព ត្រូវបានបំពេញ ប្រសិនបើវិធានដែលហាមឃាត់អំពើជាក់លាក់មួយ គឺជាច្បាប់ដែលមានសុពលភាពនៅក្នុងប្រព័ន្ធច្បាប់ដែលលើកឡើងខាងលើ។ លើសពីនេះទៀត វិធាននានានៃប្រព័ន្ធខុសៗគ្នា (ឧទាហរណ៍ ប្រព័ន្ធអន្តរជាតិ ឬយុត្តាធិការក្នុងស្រុកផ្សេងៗទៀត) មិនមែនជា 'ច្បាប់' នៅក្នុងប្រព័ន្ធច្បាប់ដែលបានលើកឡើងខាងលើឡើយ លុះត្រាតែប្រព័ន្ធអន្តរជាតិ ឬយុត្តាធិការក្នុងស្រុកផ្សេងៗទៀតនោះ ត្រូវបានអនុម័ត និងចែងផ្តន្ទាទោសព្រហ្មទណ្ឌយ៉ាងជាក់លាក់។

ឃាត់ជាទូទៅមួយ មិនឱ្យដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌលើអំពើ ឬការខកខានទាំងឡាយណាដែលមិនមែនជាបទល្មើសនៅក្នុងប្រព័ន្ធយុត្តាធិការមួយ នាពេលដែលទង្វើនោះបានប្រព្រឹត្ត ឬខកខានមិនបានប្រព្រឹត្ត[៣៣]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY បានកត់សម្គាល់ គោលការណ៍នីត្យានុកូលភាព "សំខាន់បំផុតនោះ គឺជាគោលការណ៍យុត្តិធម៌មួយ"[៣៤]។ ដូច្នេះ គោលការណ៍នេះមានបំណងធំៗចំនួនពីរ គឺ លើកកំពស់ភាពប្រាកដប្រជានៃច្បាប់ និងការពារកុំឱ្យមានការអនុវត្តអំណាចរបស់រដ្ឋដោយខុសច្បាប់[៣៥]។

១៣. គោលការណ៍នីត្យានុកូលភាពអាចអនុវត្តបានចំពោះបទល្មើស ក៏ដូចជាទម្រង់នៃការទទួលខុសត្រូវទាំងឡាយដូចមានចែងនៅក្នុងច្បាប់សារធាតុ[៣៦]។ ក្រៅពីតម្រូវឱ្យប្រកាសជាផ្លូវការថាជាអំពើបទល្មើសព្រហ្មទណ្ឌ គោលការណ៍នេះនៅទាមទារលក្ខខណ្ឌថា ជនជាប់ចោទត្រូវតែ*មានលទ្ធភាពប្រមើលមើលឃើញ*គ្រប់គ្រាន់នៅពេលដែលអំពើដូចបានចោទប្រកាន់បានប្រព្រឹត្តឡើងថា ទង្វើនេះមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ[៣៧]។ បន្ថែមពីនេះ ច្បាប់ជាក់លាក់មួយដែលចែងអំពីបទល្មើសព្រហ្មទណ្ឌបែបនេះ ត្រូវតែឱ្យគេ*ដឹងដោយទូលំទូលាយ និងមានលទ្ធ*

---

[33] សូមមើល រដ្ឋអាជ្ញា ទល់នឹង *Milutinovic* និងអ្នកផ្សេងទៀត សំណុំរឿង លេខ IT-99-37-AR72, 'សេចក្តីសម្រេចលើសំណើរបស់ Dragoljub Ojdanic ជំទាស់ទៅនឹងយុត្តាធិការ – សហឧក្រិដ្ឋកម្មរួម' ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ ('សេចក្តីសម្រេចលើរឿងក្តី Milutinovic') កថាខណ្ឌ ៣៧ (កត់សម្គាល់ថា អនុលោមតាម គោលការណ៍នីត្យា នុកូលភាព 'ការផ្តន្ទាទោសព្រហ្មទណ្ឌអាចផ្អែកតែទៅលើបទដ្ឋានមួយដែលមានអត្ថិភាពនៅពេលដែលអំពើសកម្ម ឬអកម្មត្រូវបានប្រព្រឹត្តឡើង ដែលជនជាប់ចោទត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ')។

[34] សេចក្តីសម្រេចលើរឿងក្តី Milutinovic កថាខណ្ឌ ៣៧ (ដកស្រង់ តុលាការយោធាអន្តរជាតិនៅទីក្រុងណូរ៉ែមប៊ើក)។

[35] សូមមើល W. N. Ferdinandusse, DIRECT APPLICATION OF INTERNATIONAL CRIMINAL LAW (Cambridge 2006), ទំព័រ 238 ។ កត់សម្គាល់៖ ច្បាប់ប្រតិសកម្ម ជាគោលការណ៍ មិនស៊ីគ្នាជាមួយនឹងនិយ័តភាពគតិយុត្តិឡើយ ដោយសារតែបុគ្គលមិន អាចដឹងជាមុនអំពីផលវិបាកផ្លូវច្បាប់នៃអំពើរបស់ពួកគេ លុះត្រាតែផលវិបាកទាំងនេះត្រូវបានចែងមុនព្រឹត្តការណ៍(*ex ante*) ថាជាបទល្មើសព្រហ្មទណ្ឌ។

[36] សូមមើល សាលក្រម ឌុច កថាខណ្ឌ ២៨ (ដកស្រង់ សេចក្តីសម្រេចលើរឿងក្តី Milutinovic កថាខណ្ឌ ៣៤-៤៤)។

[37] ដូចដើងទំព័រខាងលើ (ដកស្រង់ សេចក្តីសម្រេចលើរឿងក្តី Milutinovic កថាខណ្ឌ ៣៨)។

*ភាពរកច្បាប់នេះបាន*[៣៨]។ នៅក្នុងករណីទាំងពីរនេះ ការសម្រេចនោះគឺមិនត្រឹមតែអាស្រ័យលើថាតើចារីដែលត្រូវបានចោទប្រកាន់ គួរ ឬ មិនគួរបានដឹងថា អំពើរបស់ខ្លួនជាបទល្មើសព្រហ្មទណ្ឌដែរឬទេនោះទេ (ឧទាហរណ៍នៅក្នុងរឿងក្តីលើបទមនុស្សឃាត) ក៏ប៉ុន្តែវាក៏អាស្រ័យលើថាតើអំពើបែបនោះ អាចត្រូវបានគេយល់ឃើញថាស្ថិតនៅក្នុងការកំណត់បទចោទជាក់លាក់មួយដែរឬទេ (ឧទាហរណ៍ នៅក្នុងរឿងក្តីលើបទមនុស្សឃាត ដែលជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)[៣៩]។

១៤. គោលការណ៍នីត្យានុកូលភាព "រារាំងមិនឱ្យតុលាការមួយបង្កើតច្បាប់ថ្មី ឬ មិនឱ្យបកស្រាយច្បាប់ដែលមានស្រាប់ឱ្យហួសពីដែនកម្រិតដ៏សមហេតុផលនៃបទប្បញ្ញត្តិ ដែលបានចែងបញ្ជាក់ទទួលយកបានរួចហើយនោះទេ"[៤០]។ ហេតុដូច្នេះ យើងត្រូវមានការប្រយ័ត្នប្រយែងលើវិធីសាស្ត្រចំពោះបទប្បញ្ញត្តិដែលបានចែងបញ្ជាក់ច្បាស់បែបនេះរួចហើយ[៤១] ដោយសារការបកស្រាយ និងការវិវឌ្ឍន៍ មានព្រំដែនមួយច្បាស់លាស់ ហើយការវិវឌ្ឍន៍នៃច្បាប់

---

[38] ដូចជើងទំព័រខាងលើ។

[39] ដូចគ្នានេះដែរ ចរិកលក្ខណៈសាហាវយង់ឃ្នងនៃអំពើដែលបានលើកឡើងនោះ អាចទាក់ទិននឹងឧក្រិដ្ឋភាព របស់ពួកគេ (ដូច្នេះ ក៏ទាក់ទិនផងដែរទៅនឹងភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ ប៉ុន្តែ ដោយផ្ទុយទៅនឹងគោលជំហររបស់ ស.ច.ស (ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០២) វាមិនទាក់ទិនទៅនឹងបញ្ហាថាតើលក្ខណៈសម្បត្តិជាក់លាក់ណាក៏ដោយនៃអំពើបែបនោះ អាចប្រមើលដឹងជាមុនដូចគ្នា ឬយ៉ាងណានោះឡើយ។

[40] សេចក្តីសម្រេចលើរឿងក្តី Milutinovic កថាខណ្ឌ ៣៨។

[41] សូមមើល ឧទាហរណ៍ សាលក្រម ឌុច កថាខណ្ឌ ៣៤ ('គោលការណ៍នីត្យានុកូលភាព មិនបានហាមឃាត់ដល់អង្គជំនុំជម្រះក្នុងការកំណត់លើបញ្ហាណាមួយ តាមរយៈដំណើរការនៃការបកស្រាយ និងការបញ្ជាក់លើធាតុផ្សំនៃបទល្មើសណាមួយនោះទេ។ ហើយគោលការណ៍នេះក៏មិនបានហាមឃាត់អង្គជំនុំជម្រះមិនឱ្យផ្អែកលើសេចក្តីសម្រេចដែលសមស្រប ដែលសេចក្តីសម្រេចនោះបកស្រាយអំពីធាតុផ្សំជាក់លាក់នៃបទល្មើសណាមួយនោះដែរ។ ជាពិសេស ការពឹងផ្អែករបស់អង្គជំនុំជម្រះលើសេចក្តីសម្រេចរបស់តុលាការអន្តរជាតិនានា ដែលសម្រេចក្រោយខែមករា ឆ្នាំ១៩៧៩ មិនផ្ទុយនឹងគោលការណ៍នីត្យានុកូលភាពទេ។ ប៉ុន្តែ សេចក្តីសម្រេចទាំងនេះផ្តល់នូវការណែនាំបកស្រាយទាក់ទងនឹងស្ថានភាពវិវត្តន៍នៃឧក្រិដ្ឋកម្មមួយចំនួន និងទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិ')។

ព្រហ្មទណ្ឌសារធាតុ អាចមានភាពផ្ទុយគ្នាដោយផ្ទាល់នឹងលក្ខខណ្ឌនៃលទ្ធភាពដែលអាចប្រមើលមើលឃើញថាមានច្បាប់[៤២]។

## ២. ក្របខណ្ឌអន្តរជាតិ

១៥. នៅក្នុងក្របខណ្ឌអន្តរជាតិ គោលការណ៍នីត្យានុកូលភាពគឺជាផ្នែកមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("កតិកាសញ្ញាអន្តរជាតិ")[៤៣] ដែលចែងដូចតទៅ៖

> គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ[៤៤]។
>
> គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ[៤៥]។

បទប្បញ្ញត្តិទាំងនេះត្រូវបានយកមកប្រើប្រាស់មួយផ្នែកជាមូលដ្ឋានសម្រាប់ការចោទប្រកាន់នៅសាលាក្តី ICTY សាលាក្តី ICTR សាលាក្តី SCSL និងតុលាការ ICC[៤៦]។ នៅពេលបញ្ជាក់អំពីយុត្តាធិការរបស់សាលាក្តីទាំងនេះលើកម្មវត្ថុនៃរឿងក្តី ដែលរបបច្បាប់ព្រហ្មទណ្ឌជាតិមិនអាចអនុវត្តបាន[៤៧] អង្គជំនុំជម្រះបានពិនិត្យមើល (នៅក្នុងចំណុចដទៃៗទៀត) ថាតើ

---

[42] គោលការណ៍នីត្យានុកូលភាព ទាក់ទិននឹងមូលដ្ឋានគតិយុត្តិសម្រាប់ការចោទប្រកាន់ នោះគឺជាឧក្រិដ្ឋភាពនៃអំពើបែបនោះ។ វាគឺជាមូលដ្ឋានគតិយុត្តិដែលគួរតែត្រូវបានវិនិច្ឆ័យនៅពេលដែលបទឧក្រិដ្ឋបានកើតឡើង។

[43] ឆ្នាំ១៩៩៦ សេចក្តីសម្រេចរបស់មហាសន្និបាត 2200A (XXI), 21 UN GAOR Supp (No. 16) ត្រង់ចំណុច 52, UN Doc A/6316 (1966), 999 UNTS 171

[44] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៥(១)។

[45] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៥(២)។

[46] សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង *Delalic* និងអ្នកផ្សេងទៀត សំណុំរឿង លេខ IT-96-21-A, 'សាលក្រម' ចុះថ្ងៃ ទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ១៧៩។

[47] សូមមើល ឧទាហរណ៍ សេចក្តីសម្រេចលើរឿងក្តី Milutinovic កថាខណ្ឌ ៤០ ('តុលាការនេះមិនបានយកច្បាប់របស់អតីតយូហ្គោស្លាវីមកអនុវត្តចំពោះនិយមន័យនៃបទឧក្រិដ្ឋ និងទម្រង់នានានៃការទទួលខុសត្រូវនៅក្នុងយុត្តាធិការរបស់ខ្លួនឡើយ។ ដូចដែលបានគូសបញ្ជាក់ខាងលើ តុលាការនេះអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាក់ទិនទៅនឹងយុត្តាធិការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

បទល្មើសទាំងនេះ និងទម្រង់នៃការទទួលខុសត្រូវ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នាពេលដែលបទល្មើសដូចបានចោទប្រកាន់បានកើតឡើង ដែរឬទេ[៤៨]។

១៦. នៅពេលបញ្ជាក់អំពីយុត្តាធិការរបស់សាលាក្តីនេះលើកម្មវត្ថុនៃរឿងក្តី ក.ស.ច.ស[៤៩] អ.ប.ជ[៥០] និង អ.ជ.ស.ដ[៥១] បានយោងលើគោលការណ៍នីត្យានុកូលភាពនៅក្នុងក្របខណ្ឌអន្តរជាតិ។

---

*ទៅលើរឿងក្តី* (*ratione materiae)*') កត់សម្គាល់៖ តុលាការអន្តរជាតិបានពិនិត្យមើលទៅលើច្បាប់ជាតិដែលពាក់ព័ន្ធនៅក្នុងការធ្វើវិភាគអំពីភាពអាចប្រមើលដឹងជាមុនបាន។ សូមមើល ឧទាហរណ៍ សេចក្តីសម្រេចលើរឿងក្តី Milutinovic កថាខណ្ឌ ៤០ ('[តុលាការ ICTY] អាច [...] ប្រើប្រាស់ច្បាប់ជាតិក្នុងគោលបំណងដើម្បីកំណត់ថា ជនជាប់ចោទអាចបានដឹងដោយសមហេតុផលថា បទល្មើសដែលបានលើកឡើង ឬបទល្មើសដែលត្រូវបានប្រព្រឹត្តឡើងតាមបែបដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានហាមឃាត់ និងអាចផ្តន្ទាទោសបាន។ នៅក្នុងករណីបច្ចុប្បន្ននេះ [...] ច្បាប់របស់សាធារណៈរដ្ឋសហព័ន្ធយូហ្គោស្លាវី ដែលមានជាធរមាននៅពេលនោះ បានចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលអាចប្រមើលមើលដឹងជាមុនរបស់អ្នកផ្សេងទៀត ក្នុងពាក្យពេចន៍ស្រដៀងគ្នាទៅនឹងពាក្យពេចន៍ ដែលត្រូវបានប្រើដើម្បីកំណត់និយមន័យសហឧក្រិដ្ឋកម្មរួម')។ សាលដីកាស្តីពី JCE កថាខណ្ឌ ៤៥ ('បញ្ហាចោទថាតើ JCE គឺជាទម្រង់នៃការទទួលខុសត្រូវដែលបានទទួលស្គាល់នៅក្នុងច្បាប់ជាតិដែរឬយ៉ាងណា បញ្ហាចោទនេះអាចមានលក្ខណៈពាក់ព័ន្ធនៅពេលកំណត់ថាតើជនត្រូវចោទអាចប្រមើលដឹងថាតើទង្វើដែលចោទប្រកាន់លើខ្លួន អាចនាំឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែរឬទេ') ។

[48] សូមមើល ឧទាហរណ៍ សេចក្តីសម្រេចលើរឿងក្តី Milutinovic កថាខណ្ឌ ៩ ('អង្គហេតុដែលបទល្មើសមួយមានចែងនៅក្នុងលក្ខន្តិកៈ មិនបានបង្កើតជាច្បាប់ថ្មីឡើយ ហើយតុលាការគ្រាន់តែមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មដែលបានចែង ប្រសិនបើឧក្រិដ្ឋកម្មនោះត្រូវបានទទួលស្គាល់ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលដែលមានការចោទប្រកាន់ថាឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើង។ ដូច្នេះ វិសាលភាពនៃយុត្តាធិការទៅលើរឿងក្តី (*ratione materiae)* របស់តុលាការ អាចនិយាយបានថាត្រូវបានកំណត់ដោយលក្ខន្តិកៈ ដែលចែងអំពីក្របខណ្ឌយុត្តាធិការនៃតុលាការអន្តរជាតិ និងត្រូវបានកំណត់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអំណាចរបស់តុលាការក្នុងការផ្តន្ទាទោសជនជាប់ចោទអំពីបទឧក្រិដ្ឋណា មួយដែលមានចែងនៅក្នុងលក្ខន្តិកៈ ផ្អែកទៅលើអត្ថិភាពរបស់វា *ជា*ទំនៀមទម្លាប់នៅពេលដែលមានការចោទប្រកាន់ថា បទឧក្រិដ្ឋនេះត្រូវបានប្រព្រឹត្តឡើង')។ ដូចដើងទំព័រខាងលើ កថាខណ្ឌ ១០ ('គោលការណ៍នីត្យានុកូលភាពតម្រូវថា តុលាការត្រូវអនុវត្តច្បាប់ដែលចងកាតព្វកិច្ចទៅលើបុគ្គលឱ្យប្រតិបត្តិតាម នៅពេលអំពើដែលត្រូវបានចោទប្រកាន់។ ហើយ ដូចជានៅក្នុងករណីទាក់ទិននឹងយុត្តាធិការទៅលើរឿងក្តី (*ratione materiae)* របស់តុលាការ ដែលតួអង្គច្បាប់ត្រូវតែ បានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ')។ និងដូចជើងទំព័រខាងលើ កថាខណ្ឌ ១១ ('ដូច្នេះ អ្វីដែលត្រូវតែបានកំណត់នៅក្នុងរឿងក្តីនេះ នៅពេលដែលមានការចោទប្រកាន់ថាអំពើត្រូវបានប្រព្រឹត្តឡើងនោះ គឺថាតើសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវដែលមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរឬយ៉ាងណា')។

### ៣. ក្របខណ្ឌជាតិ

១៧. ការអនុវត្តរបស់រដ្ឋដ៏ស៊ីសង្វាក់គ្នា បង្ហាញថា យុត្តាធិការជាតិអនុវត្តគោលការណ៍នីត្យានុកូលភាព ដែលមានលក្ខណៈតឹងរ៉ឹងខ្លាំងជាងយុត្តាធិការអន្តរជាតិដូចដែលបានរៀបរាប់រួចខាងលើ[52]។ នៅក្នុងក្របខណ្ឌជាតិ ដើម្បីអាចឱ្យបទល្មើសអន្តរជាតិមួយ (មិនថាផ្អែកលើមូលដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ សន្ធិសញ្ញានោះទេ) ទទួលឋានៈជាបទល្មើសជាតិមួយនោះ បទល្មើសនោះ ត្រូវកំណត់ជាផ្លូវការថាជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រព័ន្ធច្បាប់ជាតិជាមុនសិន[53]។ ហេតុដូច្នេះ ការព្យាយាមកំណត់អាកប្បកិរិយាមួយថាជាបទល្មើស ដោយផ្អែកច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលកម្ពុជាមិនបានផ្តល់សច្ចាប័ន ឬច្បាប់សន្ធិសញ្ញា មិនអាចធ្វើបាននៅកម្រិតប្រទេសឡើយ[54]។

១៨. វិធីសាស្ត្រដ៏តឹងរ៉ឹងនេះបានបង្ហាញតាមរយៈភស្តុតាងថា តុលាការរបស់រដ្ឋមួយចំនួនបានសម្រេចថា ការចោទប្រកាន់លើបទល្មើសអន្តរជាតិតាមអានុភាពប្រតិសកម្ម នៅពេលដែលច្បាប់ជាតិមិនបានកំណត់អំពើទាំងនេះថាជាបទល្មើសព្រហ្មទណ្ឌនោះ គឺជាការរំលោភលើ

---

49 សូមមើលដីកាដំណោះស្រាយ កថាខណ្ឌ ១៣០២ (យោងតាមគោលការណ៍នីត្យានុកូលភាព 'គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិឬច្បាប់អន្តរជាតិនៅខណៈពេលប្រព្រឹត្តនោះឡើយ')។ (សេចក្តីបញ្ជាក់បន្ថែម) (ដកស្រង់ *ក្នុងចំណោមប្រការផ្សេងទៀត* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)មាត្រា ១៥)។

50 សូមមើលសាលដីកាស្តីពី JCE កថាខណ្ឌ ៤៣ *et seq* (ដកស្រង់ *ក្នុងចំណោមប្រការផ្សេងទៀត* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)មាត្រា ១៥)។

51 សូមមើល សាលក្រម ឌុច កថាខណ្ឌ ២៦ *et seq* (ដកស្រង់ *ក្នុងចំណោមប្រការផ្សេងទៀត* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)មាត្រា ១៥)។

52 សូមមើល ឧទាហរណ៍ Ferdinandusse ដូចឯកសារយោង៣៥ ទំព័រ ២៣០។

53 សូមមើល K. Bremer, 'Nationale Strafvervolging Internationaler Verbrechen Gegen das Humanitaire Völkerrecht' (Lang 1999), ទំព័រ148, 256, 303–304 (សន្និដ្ឋានថា គោលការណ៍នីត្យានុកូលភាពជាតិ ហាមឃាត់មិនឱ្យអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ឡើយនៅក្នុងប្រទេសប៊ែលហ្សិក ប្រទេសអាល្លឺម៉ង់ និងប្រទេសស្វីស); Ferdinandusse ដូចឯកសារយោង៣៥ខាងលើ ទំព័រ ២៦៦។

54 ដូចជើងទំព័រខាងលើ។

គោលការណ៍*មិនមានបទល្មើស* របស់រដ្ឋទាំងនោះ[៥៥]។ ករណីបែបនេះបញ្ជាក់ថា តុលាការជាតិទាំងឡាយទំនងជាចាត់ទុកបទដ្ឋានទំនៀមទម្លាប់ថាជាបទដ្ឋាន ដែលមិនមានអានុភាពអនុវត្តដោយស្វ័យប្រវត្តិឡើយ ដោយសារវាគ្មានភាពច្បាស់លាស់[៥៦]។ ហេតុដូច្នេះ ច្បាប់ជាតិដែលកំណត់ជាក់លាក់ថាបទល្មើសមួយជាបទល្មើសព្រហ្មទណ្ឌ គឺជាបុរេលក្ខខណ្ឌចាំបាច់មួយដើម្បីអាចឱ្យអនុវត្តគោលការណ៍ព្រហ្មទណ្ឌអន្តរជាតិនៅក្នុងប្រព័ន្ធច្បាប់ជាតិបាន[៥៧]។

១៩. រដ្ឋទាំងនោះ ដែលបានព្យាយាមអនុវត្តយុត្តាធិការរបស់ខ្លួនតាមអានុភាពប្រតិសកម្មលើបទល្មើសអន្តរជាតិ បានអនុវត្តហួសសមត្ថកិច្ចនៃការត្រឹមតែបញ្ជាក់យុត្តាធិការ ដោយកំណត់

---

[55] សូមមើល *Public Prosecutor v Misrad Repak*, Oslo District Court, Case No 08-018985MED-OTIR/08, ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌ៦-៩។ ចលនាប្រឆាំងនឹងជាតិនិយម និងសម្រាប់មិត្តភាពប្រជាជន *v Aussaresses*, Court of Cassation, Appeal Judgment, Appeal no 02-80719, សាលក្រមលេខ 122, ILDC 775 (FR 2003); *Re Habré*, Appeal Decision, Cassation No 14, ILDC 164 (SN 2001), កថាខណ្ឌ៣៣; East Timor, Court of Appeal, *Armando dos Santos,* Applicable Subsidiary Law Decision, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣, ទំព័រ១៤; N and Military Prosecutor of the Military Tribunal of First Instance 2 v Military Appeals Tribunal 1A, Cassation Judgment, ILDC 349 (CH 2001); *Nulyarimma v Thompson*, [1999] FCA 1192; *Bouterse*, Judgment on Appeal, HR 00749/01 CW 2323, ILDC 80 (NL 2001), កថាខណ្ឌ 4.3.2. *Cf. Spain, High Court, Public Prosecutor's Office v Scilingo Manzorro,* Case No 16/2005 'Final Appeal Judgment', ILDC 136 (ES 2005), ដែលបានប្រកាន់យកថាការនុវត្តបទដ្ឋានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនរំលោភគោលការណ៍នីត្យានុកូលភាពរបស់ ប្រទេសអេស្ប៉ាញដែលក្រមព្រហ្មទណ្ឌមិនដាក់ទោសព្រហ្មទណ្ឌចំពោះបទល្មើសបែបនេះ រហូតទាល់តែបន្ទាប់ពីព្រឹត្តិការដែលកំពុងចោទ ពីព្រោះបទល្មើសបានកើតមានដូចបទដ្ឋាន *ius cogens* របស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលជាផ្នែកនៃច្បាប់ប្រទេសអេស្ប៉ាញ។

[56] សូមមើល PATRICK DAILLIER, DROIT INTERNATIONALE PUBLIC, 5 ED (1994), កថាខណ្ឌ 227។ ទាក់ទិននឹងការយកវិធានច្បាប់ព្រហ្មទណ្ឌអន្តរជាតិមកអនុវត្តក្នុងប្រព័ន្ធច្បាប់ជាតិ គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង និងនិយ័តភាពគតិយុត្តិ ជាទូទៅត្រូវបានចាត់ទុកថាជាមូលដ្ឋានដ៏ចំបងដែលគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មាន ច្បាប់ចែង និងនិយ័តភាពគតិយុត្តិ ហាមឃាត់ប្រកបដោយប្រសិទ្ធភាពមិនឱ្យមានការដាក់បញ្ចូល*ដោយផ្ទាល់* នូវវិធាន ទំនៀមទម្លាប់ដែលមិនមានចែងជាលាយលក្ខណ៍អក្សរទៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិ។ សូមមើល [S. Stirling-Zanda, *The determination of customary international law in European Courts,* in: *Non-State Actors and International Law* (2004),ទំព័រ 6.]

[57] S Stirling-Zanda, លេខយោង៥៦ខាងលើ ទំព័រ 13។

យ៉ាងច្បាស់ថាទង្វើដែលពាក់ព័ន្ធគឺជាបទល្មើសព្រហ្មទណ្ឌ[៥៨] ។ ជាការពិត ការផ្តល់យុត្តាធិការលើកម្មវត្ថុនៃរឿងក្តីទៅឱ្យតុលាការជាក់លាក់មួយ មិនមែនមានន័យថាតុលាការនោះអាចកំណត់ទង្វើទាំងឡាយរបស់ជនជាប់ចោទថាជាបទល្មើសព្រហ្មទណ្ឌឡើយ[៥៩] ។ ជាពិសេសនៅ

---

[58] សូមមើលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម(Can), SC 2000 c 24 មាត្រា៦។ Coroners and Justice Act 2009, ផ្នែក 70 (United Kingdom), ឥឡូវផ្នែក 65A(2) (វិសោធនកម្ម) ICC Act។ *Kononov v Latvia*, ECtHR Case No 36376/04, 'Judgment', ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០, កថាខណ្ឌ១៩៦។ សំណើវិសោធនកម្មឧក្រិដ្ឋកម្មអន្តរជាតិហូឡង់មានក្នុង 'Wijziging van het Wetboek van Strafrecht, het Wetboek van Strafvordering, de Wet internationale misdrijven, de Wet overlevering inzake oorlogsmisdrijven en enige aanverwante wetten (verruiming mogelijkheden tot opsporing en vervolging van internationale misdrijven), memorie van Toelichting (៧ ខែកញ្ញា ឆ្នាំ២០១០)'។

[59] ឧទាហរណ៍សូមមើល Roger O'Keefe: យុត្តាធិការសកល (Universal Jurisdiction): *ការបញ្ជាក់អះអាងពីទស្សនទានជាមូលដ្ឋាន:* ទនានុប្បវត្តិយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (**International Criminal Justice 2**) (2004), 735–760 ទំព័រ ៧៣៦ ("យុត្តាធិការមិនមែនជាទស្សនទានរួមទេ ។ ផ្ទុយទៅវិញ ទាំងការអនុវត្តដែលមានជាយូរមកហើយរបស់រដ្ឋនានា និងការសរសេរទ្រឹស្តី បញ្ជាក់យ៉ាងច្បាស់ថាយុត្តាធិការ ត្រូវតែបានពិចារណាក្នុងទិដ្ឋភាពពីរផ្សេងៗគ្នា ជាពិសេស យុត្តាធិការបង្គាប់ (jurisdiction to prescribe) និងយុត្តាធិការអនុវត្ត (jurisdiction to enforce) ។ យុត្តាធិការបង្គាប់ ឬយុត្តាធិការដែលដាក់បទប្បញ្ញត្តិ (prescriptive jurisdiction)- ជួនកាលហៅថាយុត្តាធិការ "តាមបទប្បញ្ញត្តិ" (legislative' jurisdiction) - នៅក្នុងបរិបទព្រហ្មទណ្ឌ យោងចំពោះអាជ្ញាធររបស់រដ្ឋក្រោមច្បាប់អន្តរជាតិក្នុងការធានាភាពអាចអនុវត្តបាននៃច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ចំពោះអំពើដែលបានប្រព្រឹត្ត [...] យុត្តាធិការអនុវត្ត ឬការអនុវត្តតាមយុត្តាធិការ- ជួនកាលហៅថាយុត្តាធិការ "ប្រតិបត្តិ" (executive' jurisdiction) យោងចំពោះអាជ្ញាធររបស់រដ្ឋក្រោមច្បាប់អន្តរជាតិក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន [...]តាមរយៈតុលាការ ។ និយាយឱ្យសាមញ្ញជាងនេះ យុត្តាធិការបង្គាប់យោងចំពោះអាជ្ញាធររបស់រដ្ឋធ្វើឱ្យទៅជាបទល្មើសចំពោះអំពើដែលបានប្រព្រឹត្ត ហើយយុត្តាធិការអនុវត្តយោងចំពោះអាជ្ញាធររបស់រដ្ឋក្នុងការចាប់ខ្លួន ឃុំខ្លួន និងចោទប្រកាន់ ជំនុំជម្រះ និងផ្តន្ទាទោស និងដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទល្មើសដែលការធ្វើយ៉ាងដូច្នេះ គឺជាការធ្វើឱ្យជាបទល្មើស ។ ដូចខាងលើ ទំព័រ ៧៤១ ("យុត្តាធិការបង្គាប់ និងយុត្តាធិការអនុវត្តគឺឯករាជ្យដាច់ចេញពីគ្នា ។ នៅក្នុងករណីណាក៏ដោយ ភាពត្រឹមត្រូវតាមច្បាប់នៃការអនុវត្តរបស់រដ្ឋនៃច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ពុំនាំមកនូវភាពត្រឹមត្រូវតាមច្បាប់នៃវិសាលភាពនៃការអនុវត្តរបស់ច្បាប់នោះនៅកន្លែងដំបូងឡើយ ។ សូមមើល សាលក្រម ឌុច កថាខណ្ឌ ២៦ ('ថ្វីបើអង្គជំនុំជម្រះមានយុត្តាធិការលើរឿងក្តីចំពោះឧក្រិដ្ឋកម្មនានា និងទម្រង់នៃការទទួលខុសត្រូវក៏ដោយ ក៏ឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវទាំងនោះ ត្រូវតែអនុវត្តឱ្យស្របតាមគោលការណ៍នីត្យានុកូលភាព')។ កត់សម្គាល់៖ គោលជំហរនេះគឺស៊ីសង្វាក់គ្នាជាមួយនឹងគោលជំហរដែលអនុវត្តដោយ តុលាការ ICTY និង ICTR ដែលអង្គជំនុំជម្រះមានកាតព្វកិច្ចត្រូវសម្រេច ជាបញ្ហាដាច់ដោយឡែកមួយ ថាតើបទឧក្រិដ្ឋ ទាំងនោះបង្កើតបានជាផ្នែកនៃច្បាប់អន្តរជាតិដែរឬយ៉ាងណាក្នុងអំឡុងរយៈពេលដែលពាក់ព័ន្ធ ទោះបីជាមានលក្ខន្តិកៈ ដែលកំណត់

ក្នុងវិស័យច្បាប់ជាតិ ការបញ្ញត្តិច្បាប់បន្ថែម គឺជាវិធានការចាំបាច់មួយ[៦០]។ វិធីសាស្ត្រខុសគ្នានេះ ត្រូវបានទទួលស្គាល់នៅក្នុងជំនាន់តុលាការ Nuremberg ថាជាលក្ខណៈដោយឡែកមួយនៃច្បាប់ជាតិ ដែលត្រូវបានគេទុកចោល (ដោយចេតនា និងដោយចាំបាច់ក្តី)នៅក្នុងក្របខណ្ឌអន្តរជាតិ[៦១]។ ប៉ុន្តែ លក្ខខណ្ឌដែលមានលក្ខខណ្ឌរិតត្បិតជាងនេះ ដូចបានពិភាក្សាខាងលើនៅក្នុងផ្នែកនេះ នៅតែអនុវត្តនៅក្នុងស្រុកជាធរមាននាពេលសព្វថ្ងៃនេះ[៦២]។

### *៤. នៅក្នុងប្រទេសកម្ពុជា*

២០. រដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន ("រដ្ឋធម្មនុញ្ញ") ចែងយ៉ាងច្បាស់ពីការរារាំង *មិនឱ្យមានបទល្មើស* ៖ "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនជនណាមួយ និងអាចធ្វើទៅកើតលុះ

---

យុត្តាធិការលើរឿងក្តីយ៉ាងជាក់លាក់ក៏ដោយ។ សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Delalic *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-21-T, 'សាលក្រម' ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ៤១៥-៤១៧ និងរឿងក្តីរដ្ឋអាជ្ញាទល់នឹង Rutanganda សំណុំរឿងលេខ ICTR 96-3-T, 'សាលក្រម' ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៨៥-៨៦។

[60] កត់សម្គាល់៖ ដូចដែលបានកត់សម្គាល់ខាងលើ ការផ្តន្ទាទោសព្រហ្មទណ្ឌនៃអង្គនីតិបញ្ញត្តិជាផ្លូវការ មិនតម្រូវទៅលើកម្រិតអន្តរជាតិឡើយ។ នេះដោយសារតែលក្ខណៈនៃតុលាការអន្តរជាតិ និងអង្គហេតុដែលមិនមានអង្គនីតិបញ្ញត្តិអន្តរជាតិ។

[61] សូមមើល ការកាត់សេចក្តីឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធាណូរ៉េមប៊ើក ក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ ១០ វ៉ុល III (US Government Printing Office 1949)ទំព័រ ៩៧៤-៩៧៥ (ដកស្រង់ សេចក្តីសម្រេចលើរឿងក្តី Milutinovic កថាខណ្ឌ ៣៩) ('វាជាការមិនសមហេតុផលឡើយក្នុងការលើកឡើងថា វិធានដែលមានក្រោយហេតុការណ៍ (*ex post facto*) *ដែលបានជ្រួតជ្រាបដល់បណ្តារដ្ឋអាស្រ័យរដ្ឋធម្មនុញ្ញ* អាចត្រូវបានយកមកអនុវត្តចំពោះសេចក្តីសម្រេចច្បាប់កុំមិនឡ សន្ធិសញ្ញា ឬ ទំនៀមទម្លាប់នៃតុលាការអន្តរជាតិ ឬយកមកអនុវត្តចំពោះការទទួលស្គាល់ជាអន្តរជាតិដែលកើតឡើងក្រោយព្រឹត្តការណ៍។ ការព្យាយាមយកគោលការណ៍ដែលមានក្រោយព្រឹត្តការណ៍ (*ex post facto*) មកអនុវត្តចំពោះសេចក្តីសម្រេចរបស់តុលាការអំពីច្បាប់អន្តរជាតិទូទៅ គឺជាការដែលមិនអាចឲ្យច្បាប់នោះដំណើរការទៅរួចឡើយតាំងពីដំណាក់កាលដំបូង') (សេចក្តីបញ្ជាក់បន្ថែម)។

[62] សូមមើល ផងដែរ van Dijk និងអ្នកផ្សេងទៀត ដូចឯកសារយោង២៧ខាងលើ ទំព័រ ៦៦០ ('ជាថ្មីម្តងទៀត អនុលោមតាមមាត្រា ៧ [សេចក្តីពន្យល់] អាស្រ័យទៅលើថាតើបុគ្គលដែលពាក់ព័ន្ធ អាចដឹងដោយសមហេតុផល ដែរឬយ៉ាងណាថាបទល្មើសដែលបុគ្គលនោះបានប្រព្រឹត្ត ត្រូវបានហាមឃាត់ និងអាចផ្តន្ទាទោសបានក្រោមប្រព័ន្ធច្បាប់ដែលពាក់ព័ន្ធនៅពេលនោះ ដោយសារបទបញ្ញត្តិច្បាប់ជាតិ ឬដោយសារតែបទបញ្ញត្តិច្បាប់អន្តរជាតិដែលមានជាធរមានដោយផ្ទាល់ដែលមានអនុភាពផ្ទៃក្នុង')។

ត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់"[63] ហើយការជំនុំជម្រះណាមួយ "ត្រូវធ្វើឡើង [...] *ឱ្យស្របទៅតាមនីតិវិធីច្បាប់ និងច្បាប់ជាធរមាន*"[64]។ ដោយសារប្រទេសកម្ពុជាអនុវត្តប្រព័ន្ធ ទ្វិកនិយម[65] ដែលបានកំណត់យ៉ាងជាក់លាក់ដូចតទៅថា៖ "វិមតិសង្ស័យត្រូវបាន ជាប្រយោជន៍ដល់ជនជាប់ចោទ"[66]។

២១. កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ចែងធានាដូចគ្នានឹងបញ្ញត្តិដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ កម្ពុជា៖ "នីតិវិធី" ដែលអនុវត្តនៅ អ.វ.ត.ក "ត្រូវស្របជាមួយនឹងច្បាប់កម្ពុជា"[67]។ ការចោទ ប្រកាន់ ការស៊ើបអង្កេត និងការជំនុំជម្រះលើរូបបុគ្គលណាមួយត្រូវអនុវត្ត "ឱ្យស្របទៅតាម នីតិវិធីដែលមានជាធរមាន"[68]។ បទបញ្ញត្តិទាំងនេះបង្ហាញអំពីការចាប់អារម្មណ៍យ៉ាងខ្លាំងលើ ការគោរពតាមប្រព័ន្ធច្បាប់ជាតិដែលមានស្រាប់ ជាពិសេសនោះគឺ ច្បាប់ជាតិដែលទទួល ស្គាល់គោលការណ៍នីត្យានុកូលភាពដ៏តឹងរ៉ឹងមួយ។

២២. បទបញ្ញត្តិ*គ្មានបទល្មើស* នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺកាន់តែមានលក្ខណៈតឹងរ៉ឹងជាង ជំហារនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជានាពេលបច្ចុប្បន្នស្តីពីនីត្យានុកូលភាព ដែលបទបញ្ញតិនេះមាន

---

63 រដ្ឋធម្មនុញ្ញ មាត្រា ៣៨ (សេចក្តីបញ្ជាក់បន្ថែម)។

64 រដ្ឋធម្មនុញ្ញ មាត្រា ១១០ (សេចក្តីបញ្ជាក់បន្ថែម)

65 ពាក្យនេះបកប្រែតាមន័យត្រង់ពីឡាតាំងថា ៖ 'នៅពេលមានមន្ទិល ចំពោះជនជាប់ចោទ'។

66 រដ្ឋធម្មនុញ្ញ មាត្រា ៣៨។ សូមមើល ផងដែរ សាលក្រម ឌុច 'មតិជំទាស់របស់ចៅក្រម Jean-Marc Lavergne ពាក់ព័ន្ធ ទៅនឹងការកំណត់ទោស' ('មតិជំទាស់របស់ចៅក្រម Lavergne') កថាខណ្ឌ ៨ (បញ្ជាក់ថា 'នៅពេលដែលច្បាប់នេះមិន មានភាពច្បាស់លាស់ ឬមិនមានចែង ពេលនោះគេត្រូវប្រកាន់យកនូវដំណោះស្រាយដែលផ្តល់នូវប្រយោជន៍ដល់ជន ជាប់ចោទនៅពេលមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តវិធានជាក់លាក់ណាមួយនោះ'។ កត់សម្គាល់ 'គោលការណ៍ដែល គេទទួលស្គាល់ជាទូទៅថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ'។ និងដកស្រង់យុត្តិសាស្ត្រព្រហ្មទណ្ឌ អន្តរជាតិ សម្រាប់សេចក្តីសំអាងដូចខាងក្រោម ៖ 'គោលការណ៍ដែលថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ ចោទ មិនមែនអនុវត្តត្រឹមតែដើម្បីវាយតម្លៃអំពីភស្តុតាង ដែលពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទប៉ុណ្ណោះទេ។ ការ អនុវត្តគោលការណ៍នេះគឺមានលក្ខណៈទូលំទូលាយជាងនេះ និងរួមបញ្ចូលទាំងការបកស្រាយបទដ្ឋានគតិយុត្តិជាធរមាន ដែលមាន លក្ខណៈមិនច្បាស់លាស់ ឬមិនប្រាកដ')។

67 កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក មាត្រា១២(១)។ សូមមើល ផងដែរ សាលក្រម ឌុច កថាខណ្ឌ ៣៥។

68 ច្បាប់ស្តីពី អ.វ.ត.ក មាត្រា ២០ថ្មី, មាត្រា ២៣ថ្មី, មាត្រា ៣៣ថ្មី។

ភាពរឹងម៉ាំ (កុំថាឡើយនៅក្នុងភាសាបារាំង)៖ "*ច្បាប់ព្រហ្មទណ្ឌគ្មានអានុភាពជាប្រតិសកម្មទេ គឺថាបទល្មើសណា បានប្រព្រឹត្តមុនបទប្បញ្ញត្តិរបស់ច្បាប់ បទល្មើសនោះមិនអាចត្រូវនិគ្រោះដោយទោសរបស់ច្បាប់ ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ*"[៦៩]។ បន្ថែមពីនេះ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៧២ ដែលនៅមានសុពលភាពជាផ្លូវការរហូតដល់ខែមករា ឆ្នាំ១៩៧៦ បានចែងថា ច្បាប់ទាំងឡាយមានអានុភាពជាប្រតិសកម្ម[៧០] ហើយគ្មានការចោទប្រកាន់ ចាប់ខ្លួន ឬ ឃុំខ្លួនណាមួយត្រូវធ្វើឡើងឡើយ លើកលែងតែច្បាប់បានអនុញ្ញាត[៧១]។ គ្មានអញ្ញត្រកម្មណាមួយ ដូចមានចែងនៅក្នុងមាត្រា ១៥(២) នៃកតិកាសញ្ញាអន្តរជាតិ មានអត្ថិភាពនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ។

## IV. ឧទ្ធរណ៍ករណ៍

### ក. បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន

២៣. ដោយហេតុថា ដីកាដំណោះស្រាយបានបញ្ជាក់យ៉ាងច្បាស់ថា អ.វ.ត.ក មានយុត្តាធិការនៅលើទិដ្ឋភាពជាច្រើន ហេតុដូច្នេះ ជនជាប់ចោទអាចធ្វើបណ្តឹងឧទ្ធរណ៍បាន អនុលោមតាមវិធាន ៦៧(៥) និងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ លើសពីនេះ សារណាបណ្តឹងឧទ្ធរណ៍នេះ ក៏ដូចជាសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តីលើបណ្តឹងឧទ្ធរណ៍ បានដាក់ក្នុងរយៈពេលកំណត់ ស្របតាមវិធាន ៧៥ នៃវិធានផ្ទៃក្នុង។

### ខ. ស.ច.ស មានការភ័ន្តច្រឡំលើអង្គច្បាប់ នៅពេលបញ្ជាក់ថា អ.វ.ត.ក មានយុត្តាធិការលើបទល្មើសអន្តរជាតិ

#### *១. ដោយហេតុថា អ.វ.ត.ក គឺជាសាលាក្តីព្រហ្មទណ្ឌជាតិ ច្បាប់កម្ពុជា រួមទាំងគោលការណ៍នីត្យានុកូលភាពជាតិ ត្រូវអនុវត្តដោយតឹងរ៉ឹង*

[៦៩] ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា៦។

[៧០] សូមមើល រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៧២ មាត្រា ៧២។

[៧១] ដូចជើងទំព័រខាងលើ មាត្រា ៦។

២៤. អ.វ.ត.ក "ត្រូវបានបង្កើតឡើងដោយច្បាប់ ក្នុងទម្រង់ជាស្ថាប័នយុត្តាធិការ *ដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃតុលាការកម្ពុជា*"[៧២]។ ខុសពីសាលាក្តី ICTY[៧៣] សាលាក្តី ICTR[៧៤] សាលាក្តី SCSL[៧៥] តុលាការ ICC[៧៦] ដែលសាលាក្តីនីមួយៗមាន "បុគ្គលភាពគតិយុត្តិអន្តរជាតិដោយឡែកៗពីគ្នា"[៧៧] អ.វ.ត.ក ជាចម្បងនោះ គឺជាសាលាក្តីព្រហ្មទណ្ឌជាតិមួយ។ ទោះបីជាមានភាពស្រពិចស្រពិលលើបញ្ហានេះ ដោយសារតែលក្ខណៈនៃការិយាល័យ និងអង្គជំនុំជម្រះរបស់សាលាក្តីនេះក៏ដោយ[៧៨] កត្តាមួយចំនួនបានបញ្ជាក់យ៉ាងច្បាស់ថា អ.វ.ត.ក សាលាក្តីជាតិ៖

ក. *អ.វ.ត.ក* បានបង្កើតឡើងដោយច្បាប់ជាតិ (មិនមែនច្បាប់អន្តរជាតិ)ឡើយ[៧៩]។

ខ. *អ.វ.ត.ក* "ត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធនៃតុលាការកម្ពុជាដែលមានស្រាប់"[៨០]។

---

[72] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០០ (សេចក្តីបញ្ជាក់បន្ថែម)។

[73] សូមមើល លក្ខន្តិកៈតុលាការ ICTY បុព្វកថា ('ដោយបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ *ដែលប្រតិបត្តិអនុលោមតាមជំពូក VII នៃធម្មនុញ្ញអង្គការសហប្រជាជាតិ* [...]') (សេចក្តីបញ្ជាក់បន្ថែម)។

[74] សូមមើល លក្ខន្តិកៈតុលាការ ICTR បុព្វកថា ('ដោយបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ *ដែលប្រតិបត្តិអនុលោមតាមជំពូក VII នៃធម្មនុញ្ញអង្គការសហប្រជាជាតិ* [...]') (សេចក្តីបញ្ជាក់បន្ថែម)។

[75] សូមមើល កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលប្រទេសសៀរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន បុព្វកថា ('[...] ក្រុមប្រឹក្សាសន្តិសុខបានស្នើឱ្យអគ្គលេខាធិការធ្វើការចចារឱ្យមានកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលប្រទេសសៀរ៉ាឡេអូន ដើម្បីបង្កើតតុលាការពិសេស*ឯករាជ្យ*មួយ [...]') (សេចក្តីបញ្ជាក់បន្ថែម) ។ កិច្ចព្រមព្រៀងតុលាការពិសេស, 2002 (Ratification) Act, 2002, ផ្នែក ១១(២) ('តុលាការពិសេសមិនត្រូវបង្កើតឡើងជាផ្នែកនៃប្រព័ន្ធតុលាការប្រទេសសៀរ៉ាឡេអូន ឡើយ')។ ដូចជើងទំព័រខាងលើ ផ្នែក ១៣ ('បទល្មើសដែលត្រូវផ្តន្ទាទោសនៅចំពោះមុខតុលាការពិសេស មិនត្រូវបានផ្តន្ទាទោសក្នុងនាមសាធារណៈរដ្ឋសៀរ៉ាឡេអូន ឡើយ')។

[76] សូមមើល លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៤(១) (' [តុលាការICC] ត្រូវមាននីតិបុគ្គលអន្តរជាតិ')។

[77] Goran Sluiter, 'Legal Assistance to Internationalized Criminal Courts and Tribunals', in C.R.P. Romano, P.A. Nollkaemper, and J.K. Kleffner (eds) INTERNATIONALIZED CRIMINAL COURTS: SIERRA LEONE, EAST TIMOR, KOSOVO AND CAMBODIA (Oxford 2004), ទំព័រ 396 (កត់សម្គាល់ថា តុលាការ SCSL មាន 'នីតិបុគ្គលអន្តរជាតិ ហើយមិនមែនជាផ្នែក នៃប្រព័ន្ធតុលាការជាតិក្នុងប្រទេសសៀរ៉ាឡេអូន ឡើយ')។

[78] សូមមើល ឧទាហរណ៍ សាលដីកាស្តីពី JCE កថាខណ្ឌ ៤៧។

[79] សូមមើល ច្បាប់ស្តីពី អ.វ.ត.ក និងកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក ។

[80] ច្បាប់ស្តីពី *អ.វ.ត.ក* មាត្រា ២។

គ. រាជរដ្ឋាភិបាលកម្ពុជាបានបដិសេធយ៉ាងច្បាស់លើគោលគំនិតចង់បង្កើតសាលាក្ដីអន្តរជាតិមួយ[៨១] ។

ឃ. មន្ត្រីតុលាការរបស់ អ.វ.ត.ក ទាំងអស់ត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ដោយ អ.ស.ប គ្រាន់តែផ្ដល់បញ្ជីស្នើបេក្ខជនអន្តរជាតិតែប៉ុណ្ណោះ[៨២] ។

ង. ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានគូសបញ្ជាក់ថា អ.វ.ត.ក ស្ថិតនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ គឺវាការពារអធិបតេយ្យកម្ពុជា[៨៣] ។

ច. នៅក្នុងសេចក្ដីសម្រេចមួយដែលចេញនាពេលមុន ទោះបីជា អ.ប.ជ បានសម្រេចថា អ.វ.ត.ក "មានលក្ខណៈដោយឡែកពីតុលាការជាតិដទៃៗទៀតនៅក្នុងទីរដ្ឋភាពមួយចំនួន" អ.ប.ជ បានរកឃើញថា អ.វ.ត.ក ដំណើរការងាររបស់ខ្លួនជា "ស្ថាប័នឯករាជ្យមួយ *នៅក្នុងរចនាសម្ព័ន្ធនៃតុលាការកម្ពុជា*"[៨៤] ។

ឆ. ទោះបីជា (នៅក្នុងករណីលើកលែងមួយចំនួន) គេត្រូវពិនិត្យមើលវិធាននីតិវិធីដែលបានបង្កើតឡើងនៅក្នុងក្របខណ្ឌអន្តរជាតិក៏ដោយ ចំណុចចាប់ផ្ដើមនៅ អ.វ.ត.ក ជានិច្ចជាកាល គឺ "នីតិវិធី និងច្បាប់កម្ពុជាដែលមានស្រាប់"[៨៥] ។

[81] សូមមើល របាយការណ៍របស់អគ្គលេខាធិការ ស្ដីពីការជំនុំជម្រះទោសខ្មែរក្រហម ឯកសាររបស់អង្គការសហប្រជាជាតិ លេខ A/57/769 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ ៦-៧។

[82] សេចក្ដីសម្រេចក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ លេខ 040/002/2001 ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ទំព័រ ៣។

[83] ដូចជើងទំព័រខាងលើ ទំព័រ ៤។

[84] សំណុំរឿង លេខ ០០១/១៨-០៧-២០០៧-អវតក/កសចស ឯកសារលេខ C-5/45 'សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ ១៧-១៩ (សេចក្ដីបញ្ជាក់បន្ថែម)។

[85] ការទទួលស្គាល់តម្រូវការដើម្បីធានាថា ដំណើរការនីតិវិធីរបស់ អ.វ.ត.ក ប្រកាន់ខ្ជាប់ទៅនឹងបទដ្ឋានគតិយុត្តិដែលត្រូវបានទទួលស្គាល់ជាសកល លិខិតុបករណ៍ជាមូលដ្ឋានអនុញ្ញាតឲ្យមានការអនុម័តបទដ្ឋាននីតិវិធីបន្ថែមនៅក្នុងករណីកំណត់ចំនួនបី ពោលគឺនៅពេលដែល ៖ (i) ច្បាប់កម្ពុជា ឬនីតិវិធីដែលមានស្រាប់ 'ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ' (ii) 'មានភាពមិនច្បាស់លាស់ទាក់ទងនឹង' 'ការបកស្រាយ ឬការអនុវត្ត' បទប្បញ្ញត្តិជាធរមាន ឬ (iii) 'មានបញ្ហាទាក់ទងទៅនឹង' 'ភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ'។ កិច្ចព្រមព្រៀងស្ដីពី អ.វ.ត.ក មាត្រា ១២(១)។ ច្បាប់ស្ដីពី អ.វ.ត.ក មាត្រា ២០ថ្មី, មាត្រា ២៣ថ្មី, មាត្រា ៣៣ថ្មី។ នៅក្នុងករណីបែបនេះ និងនៅក្នុងតែករណីបែបនេះប៉ុណ្ណោះ គេអាចស្វែងរក 'ការណែនាំ' ក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ'។ ដូចជើងទំព័រខាងលើ។ ដូច្នេះ ការទទួលស្គាល់នីតិវិធីថ្មី ឬការដាកចេញពី 'នីតិវិធីជាធរមាន' អាចត្រូវបានធ្វើ

២៥. ករណីដែលថា យុត្តាធិការលើកម្មវត្ថុនៃរឿងក្ដីបានពង្រីករហូតដល់បទល្មើសអន្តរជាតិ ឬថា ចៅក្រមមួយចំនួនរបស់ អ.វ.ត.ក មិនមែនជាចៅក្រមជាតិនោះ វាមិនបានប្រែក្លាយ អ.វ.ត.ក ឱ្យទៅជាតុលាការអន្តរជាតិវិញនោះទេ[៨៦]។ តាមពិតទៅ ឈ្មោះរបស់សាលាក្ដីនេះ គឺ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបញ្ជាក់ករណីនេះដោយស្វ័យប្រវត្តិទៅហើយ។

២៦. ផ្ទុយពីជំហររបស់ ក.ស.ច.ស[៨៧] ទោះបីជាសាលាក្ដីនេះជាសាលាក្ដីជាតិមួយ ឬក៏អត់នោះ វាមិនសំខាន់នោះទេ។ គោលការណ៍នីត្យានុកូលភាពអនុញ្ញាតឱ្យអនុវត្តច្បាប់ទាំងឡាយណាដែល *ចងកាតព្វកិច្ចនៅក្នុងប្រព័ន្ធច្បាប់ជាតិដែលពាក់ព័ន្ធ នៅពេលដែលអំពើទាំងឡាយដូចដែលបានចោទប្រកាន់ បានកើតឡើង*[៨៨]។ ហេតុដូច្នេះ អ.វ.ត.ក ដែលមានឋានៈជាតុលាការជាតិកម្ពុជាសុទ្ធសាធនោះ ត្រូវតែអនុវត្តច្បាប់ជាតិ ដែលនៅជាធរមាននៅក្នុងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។ ច្បាប់នេះរួមទាំងវិធីសាស្ត្ររបស់កម្ពុជាចំពោះគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែងផងដែរ*[៨៩]។

---

យុត្តិកម្មដោយយោងទៅលើករណីលើកលែងផ្លូវច្បាប់ជាក់លាក់មួយ ក្នុងចំណោមករណីលើកលែងផ្លូវច្បាប់ជាក់លាក់ទាំងនេះតែប៉ុណ្ណោះ។

[86] កត់សម្គាល់៖ តុលាការជាតិ ជាទម្លាប់ អនុវត្តច្បាប់អន្តរជាតិ (ស្ថិតនៅក្រោមភាពម៉ឺងម៉ាត់នៃគោលការណ៍នីត្យានុកូលភាពជាតិរបស់តុលាការទាំងនោះ)។ ហើយវាមិនមែនចំឡែកទេសម្រាប់តុលាការជាតិដែលមានចៅក្រមអន្តរជាតិនោះ ជាពិសេសនៅក្នុងបណ្ដារដ្ឋជាសមាជិកនៃក្រុមប្រទេស Commonwealth ។

[87] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០១ (បញ្ហាថាតើ អ.វ.ត.ក ជាស្ថាប័នយុត្តាធិការជាតិ ឬអន្តរជាតិ មិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនោះទេ ដរាបណាគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* (*nullum crimen sine lege*) ត្រូវបានគោរព') ។

[88] សូមមើល សេចក្ដីសម្រេចលើរឿងក្ដី Milutinovic កថាខណ្ឌ ១០។ van Dijk et al ដូចឯកសារយោងលេខ២៧ ខាងលើ។

[89] កត់សម្គាល់៖ សំណួរថាតើ ការផ្ដន្ទាទោសព្រហ្មទណ្ឌប្រតិសកម្មនៃឧក្រិដ្ឋកម្មអន្តរជាតិ នឹងរំលោភទៅលើគោលការណ៍នីត្យានុកូលភាព ដែរឬយ៉ាងណា ដូចដែលបានគូសបញ្ជាក់ខាងលើ ចាំបាច់ត្រូវឆ្លើយដោយផ្អែកទៅលើច្បាប់ជាតិ។ ដោយសារតែ អ.វ.ត.ក គឺជាតុលាការមួយស្ថិតក្រោមច្បាប់ជាតិ និងត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធច្បាប់ជាតិ មានតែគោលការណ៍នីត្យានុកូលភាពជាតិប៉ុណ្ណោះដែលពាក់ព័ន្ធ។ ទោះបីសន្មត់ *អវតក* ត្រូវបានធ្វើឱ្យទៅជាលក្ខណៈអន្តរជាតិក៏ដោយ ក៏ក្នុងន័យអ្វីក៏ដោយច្បាប់ជាតិគឺនៅតែជាធរមាន អាស្រ័យហេតុនេះហើយគ្មានហេតុផលណាមួយមិនអនុវត្តគោលបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

00615579



## ២. ច្បាប់ព្រហ្មទណ្ឌជាតិនៅពេលហេតុការណ៍ដែលបានចោទប្រកាន់បានកើតឡើង មិនបានចែងកំណត់បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋកម្មសង្គ្រាម ជាបទល្មើសព្រហ្មទណ្ឌឡើយ

២៧. ដូចដែលបានកត់សម្គាល់ខាងលើ របបច្បាប់ជាតិជាធរមាននៅពេលហេតុការណ៍ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ បានកើតឡើង មិនបានកំណត់បទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៤ ដល់ មាត្រា ៦ នៃច្បាប់ អ.វ.ត.ក ថាជាបទល្មើសព្រហ្មទណ្ឌឡើយ។ ដោយកុំគិតពីឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ ១៩៧៩ នោះប្រព័ន្ធទ្វិកនិយមរបស់ប្រទេសកម្ពុជា ហាមឃាត់មិនឱ្យយកនិយាមអន្តរជាតិ បែបនេះ (ដែលអាច ឬ មិនអាចមានអត្ថិភាពនាពេលនោះ[៩០]) មកអនុវត្តដោយផ្ទាល់នៅក្នុងអំឡុងពេលតែមួយនោះ។ លើសពីនេះទៀត ច្បាប់អនុវត្តចំពោះបទប្រល័យពូជសាសន៍ បទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋកម្មសង្គ្រាម មិនត្រូវបានគេអនុម័តនៅមុន ឬ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ អាស្រ័យហេតុនេះ បទល្មើស អន្តរជាតិទាំងនេះ "*មិនអាចអនុវត្តបាននៅក្នុងអំឡុពេលដែលពាក់ព័ន្ធនោះទេ*"[៩១]។

---

ការណ៍ច្បាប់ជាតិរបស់កម្ពុជានោះទេ។ ក្នុងករណីដែលមានភាពផ្ទុយគ្នាកើតឡើងរវាងវិធានដែលបង្កើតឡើង និង ច្បាប់របស់ក្រុង និងបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ ទំនាស់បែបនេះត្រូវតែបានដោះស្រាយឡើងតាមគោលការណ៍ *in dubio pro reo* ដែលតាមរយៈបញ្ញាត្តិដែលជាផលប្រយោជន៍របស់ជនជាប់ចោទ។ សូមមើលកថាខណ្ឌទី២០ និង លេងយោងទី៦៨ ៦៩ ខាងលើ។

[90] សូមមើល កថាខណ្ឌ១១ ដូចឯកសារយោងខាងលើ។

[91] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០២ ('ដើម្បីអាចឱ្យអំពើមួយត្រូវចាត់ចូលជាបទល្មើសនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិក្នុងពេលដែលអំពើនោះកើតឡើងនោះទេ នោះច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ត្រូវចែងអំពីបទល្មើសនៃអំពើនោះដោយច្បាស់លាស់ ឬដោយតុល្លីភាព ហើយអំពើនោះក៏ត្រូវតែជាបទល្មើសនៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិ *ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជានៅខណៈពេលដែលអំពើនោះកើតឡើងផង*ដែរ') (សេចក្ដីបញ្ជាក់បន្ថែម)។ កត់សម្គាល់៖ គោលជំហររបស់ ស.ច.ស ទាក់ទិននឹងបញ្ហានេះ គឺត្រឹមត្រូវតាមគតិយុត្តិ។

២៨. ហេតុដូច្នេះ ជំហររបស់ ស.ច.ស ដែលបានលើកឡើងថា "បញ្ហាដែលចោទឡើងថាតើច្បាប់អន្តរជាតិអាច ឬមិនអាចអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជានឹងមិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក នោះឡើយ"[92] គឺជាការភ័ន្តច្រឡំ។ ដោយហេតុថា ច្បាប់ជាតិមិនបានចែងកំណត់ជាចាំបាច់ថាទង្វើភាគច្រើនដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយជាបទល្មើសព្រហ្មទណ្ឌ មូលដ្ឋានមួយទៀតតែមួយគត់នោះគឺការអនុវត្តច្បាប់អន្តរជាតិ។ ប៉ុន្តែ ដូចមានហេតុផលលើកឡើងនៅក្នុងកថាខណ្ឌមុនៗ ច្បាប់អន្តរជាតិទាំងនេះ មិនអាចអនុវត្តបាននៅក្នុងប្រទេសកម្ពុជានាចន្លោះឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនដែលជាផ្នែកមួយនៃប្រព័ន្ធច្បាប់ជាតិដោយផ្ទាល់នោះទេ។

២៩. ដូចគ្នានេះដែរ សេចក្តីសន្និដ្ឋានរបស់ ក.ស.ច.ស ថា នួន ជា អាចបានដឹងដោយទូលំទូលាយអំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម ពីព្រោះ នួន ជា ត្រូវបានចោទប្រកាន់ថាជាសមាជិកមួយរូបនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា[93] មិនសមស្របឡើយ។ ទោះបី នួន ជា មានប្រភពនៃច្បាប់អន្តរជាតិលើបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង/ឬ បទឧក្រិដ្ឋកម្មសង្គ្រាម នាពេលនោះក៏ដោយ "ច្បាប់" បែបនេះ មិនមានអានុភាពចងកាតព្វកិច្ចលើ នួន ជា អនុលោមតាមប្រព័ន្ធច្បាប់ជាតិកម្ពុជា"[94]។ ហេតុដូច្នេះ ករណីដែលគោលការណ៍នីត្យានុកូលភាព (ដែល ស.ច.ស យកមកធ្វើជាមូលដ្ឋាននោះ[95]) នឹងមិនរំលោភលើការចោទប្រកាន់ នួន ជា ចំពោះបទល្មើសអន្តរជាតិ គឺមិនសមស្របទេ។

### ៣. ច្បាប់ អ.វ.ត.ក មិនចែងកំណត់ថា បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋកម្មសង្គ្រាម ជាបទល្មើសព្រហ្មទណ្ឌឡើយ

---

[92] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៤។

[93] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៥-១៣០៧។

[94] សូមមើលកថាខណ្ឌ២៧ ខាងលើ។

[95] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០២។

៣0. ស.ច.ស បានសម្រេចថា "ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិក្នុងពេលដែលអំពើនោះបានកើតឡើងនោះទេ នោះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវចែងអំពីបទល្មើសនៃអំពើនោះដោយច្បាស់លាស់ ឬ ដោយតុល្យភាព ហើយអំពើនោះក៏ត្រូវជាបទល្មើសនៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិ ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា នៅខណៈពេលដែលអំពើនោះបានកើតឡើងផងដែរ"[៩៦]។ ការលើកឡើងបែបនេះមើលទៅមិនមានអ្វីខុសទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដីកាដំណោះស្រាយពិតជាលើកឡើងដោយភ័ន្តច្រឡំថា ច្បាប់ អ.វ.ត.ក បានកំណត់ថា បទល្មើសទាំងឡាយដែលបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ ជាបទល្មើសអន្តរជាតិ[៩៧]។ វាមិនមែនដូច្នេះនោះទេ។

៣១. ច្បាប់ អ.វ.ត.ក គ្រាន់តែផ្តល់យុត្តាធិការដល់សាលាក្តី លើបទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៣ (ថ្មី) ដល់ មាត្រា ៦។ ចំណុចនេះបង្ហាញឃើញច្បាស់តាមរយៈឃ្លោងឃ្លានៃបទប្បញ្ញត្តិទាំងនេះ ដែលគ្រាន់តែអនុញ្ញាតឱ្យ អ.វ.ត.ក "នាំមកកាត់សេចក្តី" ចំពោះជនជាប់ចោទពីបទបទល្មើសជាតិ បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម។ ដោយសរសេរព្រាងយុត្តាធិការនៅក្នុងភាសាមួយក្នុងលក្ខណៈកម្រិតមាត្រាទាំងនេះមិនផ្តល់អានុភាពជាបទល្មើសព្រហ្មទណ្ឌ[៩៨] អនុលោមតាមច្បាប់សារធាតុ ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ឡើយ។

៣២. សញ្ញាណដែលលើកឡើងថា បទបញ្ញត្តិស្តីពីយុត្តាធិការចែងកំណត់ដោយតុល្យភាពថា បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងប្រទេសកម្ពុជា ជាបទល្មើសព្រហ្មទណ្ឌនោះ សញ្ញាណនេះប៉ះពាល់លើលក្ខខណ្ឌនៃភាពអាចប្រមើលមើលឃើញ និងភាពអាចដឹងយ៉ាងទូលំទូលាយថាមានច្បាប់ចែងនៃគោលការណ៍នីត្យានុកូលភាព។ លើសពីនេះទៀត គោលការណ៍នេះបានបែងចែកពីភាពខុសគ្នាយ៉ាងខ្លាំង

---

96 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣0២។

97 សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ១៣0៥ ទៅ ១៣0៧។

98 សូមមើល O'Keefe លេខយោង៥៩ខាងលើ អំពីការញែករវាងយុត្តិការដើម្បីបង្គាប់ និងយុត្តិការបង្ខំ។

00615582



រវាងយុត្តាធិការ និងមូលដ្ឋាននៃបទល្មើសព្រហ្មទណ្ឌ អនុលោមតាមច្បាប់សារធាតុ[៩៩]។ បើទោះជាការប្រែប្រួលជាអានុភាពប្រតិសកម្មនៃលក្ខខណ្ឌនៃការចោទប្រកាន់ ដែលមិនមែនសម្រាប់ ការកំណត់បទល្មើសព្រហ្មទណ្ឌ (ឧទាហរណ៍ បទបញ្ញត្តិស្តីពីនីតិវិធី ឬយុត្តាធិការ) ជាទូទៅ គឺមិនស្ថិតនៅក្រោមគោលការណ៍នីត្យានុកូលភាព[១០០] ការប្រែប្រួល *ក្រោយព្រឹត្តហេតុ* ចំពោះច្បាប់សារធាតុ គឺស្ថិតនៅក្រោមគោលការណ៍នេះ[១០១]។ ដោយសារភាពខុសគ្នានេះ វាមិនសម ហេតុផលទេក្នុងការទាញការសន្និដ្ឋានបទល្មើសព្រហ្មទណ្ឌចេញពីយុត្តាធិការ។ និយាយឱ្យងាយទៅ វិសាលភាពនៃបទល្មើសព្រហ្មទណ្ឌរវាងការប្រព្រឹត្តិបទល្មើសដែលបានចោទប្រកាន់ និងការចោទប្រកាន់នាពេលក្រោយនោះ មិនគួរត្រូវបានគេពង្រីកឡើយ[១០២]។

### *៤. គោលការណ៍នីត្យានុកូលភាពអន្តរជាតិ មិនចែងកំណត់អំពីបទល្មើសព្រហ្មទណ្ឌជាតិ*

---

99 ដូចលេខយោងខាងលើ។

100 សូមមើលករណីរាជអាជ្ញាទល់នឹង *Kallon*, Case No SCSL-04-14-AR72, "សេចក្តីសម្រេចលើធម្មនុញ្ញភាព និងកង្វះខាតយុត្តាធិការ" ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤, កថាខណ្ឌ៨២ ("ការពិតដែលគ្មានតុលាការណាមានយុត្តាធិការដើម្បីកាត់សេចក្តីបទល្មើបដិសេធដោយច្បាប់អន្តរជាតិនៅពេលដែលបទល្មើសកើតឡើង ដែលមិនមែនជាការរាំងរល់ការកាត់ទោស និងមិនមែនជាការរំលោភរលល់គោលការណ៍ *nullum crimen sine lege.*'); សូមមើលផងដែរ សាលក្រម Delalic, កថាខណ្ឌ១៧៩-១៨០; *cf Streletz, Kessler, and Krenz v Germany*, ECtHR Case Nos 34044/96 & 35532/97 & 44801/98, "សាលក្រម", ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០១, កថាខណ្ឌ៧៩-៨១; សាលក្រមខុច កថាខណ្ឌ៣៤។

101 សូមមើល RUTH A. KOK, STATUTORY LIMITATIONS IN INTERNATIONAL CRIMINAL LAW (Asser 2001), ទំព័រ ២៩១-២៩២។

102 *See* FERDINANDUSSE, លេខយោង៣៥ខាងលើ, ទំព័រ ២២៣។ សូមមើល ផងដែរ [តុលាការធម្មនុញ្ញប្រទេសប៊ែលហ្សិក Erdal ទល់នឹង ក្រុមប្រឹក្សារដ្ឋមន្ត្រី សេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញ លេខ 73/2005; ILDC 9 (BE 2005) par. B7 (សម្រេចថា គោលការណ៍នៃ អានុភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានឥទ្ធិពលទៅលើការពង្រីកវិសាលភាពតាមទីកន្លែង (*ratione loci*) នៃបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌដែលមានពីមុនស្រាប់៖ ច្បាប់ដែលពង្រីកវិសាលភាពតាមទីកន្លែង (*ratione loci*) នៃបទឧក្រិដ្ឋ ដែលមានចែងរួចហើយនៅក្នុងក្រមព្រហ្មទណ្ឌ (ប្រទេសប៊ែលហ្សិក) ('ក្រមព្រហ្មទណ្ឌ') គឺជាច្បាប់សារធាតុ ដែលច្បាប់ទាំងនោះបានបង្កើតនូវមូលដ្ឋានគតិយុត្តិសម្រាប់ការចោទប្រកាន់នៅក្នុងប្រទេសប៊ែលហ្សិក។ ដូច្នេះ ច្បាប់ទាំងនោះមិនអាច យកមកអនុវត្តជាប្រតិសកម្មបានឡើយ)]។

៣៣. ទោះបីវាគិតគួរអំពីការចោទប្រកាន់នៅក្នុងស្រុកលើបទល្មើសអន្តរជាតិនៅក្នុងករណីមួយចំនួនក៏ដោយ គោលការណ៍នីត្យានុកូលភាពអន្តរជាតិ ទោះបីវាមានអត្ថិភាពក៏ដោយ ក៏មិនអាចបញ្ចូលបទល្មើសព្រហ្មទណ្ឌ អនុលោមតាមច្បាប់សារធាតុ ចូលទៅក្នុងប្រព័ន្ធច្បាប់ជាតិដែលមានស្រាប់នោះឡើយ។ ដូចតាមរយៈភស្តុតាងនៃការអនុវត្តរបស់រដ្ឋដែលបានពិភាក្សាមុនៗ[១០៣] គោលការណ៍*មិនមានបទល្មើស* អន្តរជាតិ ស្ថិតនៅក្រោមចំណុះអធិបតេយ្យជាតិ (រួមទាំងគោលការណ៍នីត្យានុកូលភាពរបស់ប្រទេសកម្ពុជាខ្លួនឯងផងដែរ)។ ការលើកគោលការណ៍ នេះឡើង (មិនថាមានចេតនាល្អបែបណាឡើយនោះ[១០៤]) តាមនិយាម មិនមានអានុភាពលើច្បាប់ជាតិឡើយ ប្រសិនបើច្បាប់ជាតិមិនបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ។ ហេតុដូច្នេះ មាត្រា ៣៣(២)នៃច្បាប់ អ.វ.ត.ក ដែលចែងយោងលើមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិ មិនបានធ្វើឱ្យបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋកម្មសង្គ្រាម ក្លាយជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាឡើយ ពីព្រោះតែបទល្មើសអន្តរជាតិទាំងនេះមិនអាចអនុវត្តបានឡើយនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។

---

[103] សូមមើលកថាខណ្ឌ១៧ដល់១៩ ខាងលើ។

[104] សូមមើល សាលដីកាស្តីពី JCE កថាខណ្ឌ ៤៧ (អង្គបុរេជំនុំជម្រះយល់ឃើញថា ឋានៈរបស់ អ.វ.ត.ក 'មិនមានផលប៉ះពាល់លើដីកាដែលត្រូវបានជំទាស់ ដែលសម្រេចថា [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] អាចអនុវត្តបានចំពោះមុខ អ.វ.ត.ក។ វាពិតជាមិនមានផលប៉ះពាល់មែន នៅពេលពិចារណាពាក្យច្បាស់លាស់នៃមាត្រា១ និងមាត្រា២ នៃច្បាប់ អ.វ.ត.ក ដែលគោលបំណងនៃច្បាប់នេះ គឺដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះ [...] ការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិនិងទំនៀមទម្លាប់អន្តរជាតិ ដែលទទួលស្គាល់ដោយប្រទេសកម្ពុជា [...]។ នៅក្នុងករណីនេះ ច្បាប់អ.វ.ត.ក ក៏ចែងយ៉ាងច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញត្រូវតែបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ក្នុងគោលបំណងនេះ')។ កត់សម្គាល់៖ ចំពោះហេតុផលដែលបានពិភាក្សាដោយសង្ខេបនេះ បំណងប្រាថ្នា និងគោលបំណងតែមួយគត់ដើម្បី 'កាត់សេចក្តី' ចារីដែលត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មអន្តរជាតិ គឺជាយុត្តិកម្មមិនគ្រប់គ្រាន់ សម្រាប់ការកំណត់ (ដោយមានគោលបំណង) ថាជាបទល្មើសព្រហ្មទណ្ឌជាតិ។ អំណះអំណាងរបស់ អ.ប.ជ នៅក្នុងករណីនេះផ្តល់ជាយោបល់ថា ឆន្ទៈនយោបាយបច្ចុប្បន្ននេះ គួរតែមានសារសំខាន់ជាងគោលការណ៍ច្បាប់ដែលបានកំណត់។

៣៤. សម្រាប់ហេតុផលទាំងនេះ ព្រមទាំងហេតុផលនៅផ្នែក IV ខ ២-៣ (កថាខណ្ឌ២៧-៣២) មិនអាចនិយាយបានទេថា បទល្មើសបានយោងលើមាត្រាទី៤-៦ នៃច្បាប់អវតក គឺជាទោសព្រហ្មទណ្ឌក្នុងប្រទេសកម្ពុជាក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនោះទេ។ អាស្រ័យហេតុនេះ ហើយការចោទប្រកាន់លោក នួន ជា លើឧក្រិដ្ឋកម្មដែលមិនមានក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ នឹងរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់។

### *៥. ការកំណត់បទល្មើសព្រហ្មទណ្ឌដោយអានុភាពប្រតិសកម្ម រំលោភលើគោលការណ៍នីត្យានុកូលភាពជាតិ*

៣៥. ក្នុងគោលបំណងបង្ហាញទឡ្ហីករណ៍ យើងសន្មតថា អង្គជំនុំជម្រះនេះជឿថា ច្បាប់ អ.វ.ត.ក បានកំណត់បទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៤ ដល់ មាត្រា ៦ ថាជាបទល្មើសព្រហ្មទណ្ឌ ច្បាប់ធ្វើឡើងតាមអានុភាពប្រតិសកម្មបែបនេះរំលោភលើគោលការណ៍នីត្យានុកូលភាពរបស់ប្រទេសកម្ពុជា[១០៥]។

៣៦. ការធ្វើឱ្យទៅជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើកើតមុន នៅក្នុងប្រព័ន្ធច្បាប់មួយ ខកខានបំពេញលក្ខខណ្ឌនៃភាពអាចប្រមើលមើលឃើញថាមាន គោលការណ៍ *មិនមានបទល្មើស* ជាតិ។ តាមទឡ្ហីករណ៍ បើទោះជាអាញ្ញត្រកម្មចំពោះគោលការណ៍នីត្យានុកូលភាពអន្តរជាតិ

[105] សូមមើលករណី O'Keefe, លេខយោង៥៩ ខាងលើ, នៅទំព័រ៧៤៣ ("ការអនុវត្តន៍យុត្តាធិការបញ្ញត្តិដោយផ្អែកលើមូលដ្ឋាននៃទំនាក់ទំនងផ្នែកយុត្តាធិការដែលបានបង្កើតនូវការទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើស គឺជាទម្រង់មួយនៃការដាក់ទោសព្រហ្មទណ្ឌដែលមានប្រតិសកម្ម ដូច្នេះអ្វីដែលមិនអាចទទួលយកបាននោះ គឺដោយសារតែបំរាមផ្នែកព្រហ្មទណ្ឌថ្នាក់ជាតិលើអង្គសេចក្តី និងការដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្ត ហើយវាក៏មិនមែនគ្រាន់តែជាសមត្ថកិច្ចដែលទាក់ទងនឹងនីតិវិធីថ្នាក់ជាតិប៉ុណ្ណោះទេ ពោលគឺទម្រង់នៃការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌបែបនេះអាចយកទៅអនុវត្តលើជនជាប់ចោទបានបន្ទាប់តែពីមានការប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ។ [...] ការអនុវត្តយុត្តាធិការបញ្ញត្តិរបស់រដ្ឋមួយដោយផ្អែកទៅលើទំនាក់ទំនងផ្នែកយុត្តាធិការ មិនត្រូវបានបំពេញឡើយ រហូតបន្ទាប់ពីមានការប្រព្រឹត្តបទល្មើស មានន័យថា ក្នុងខណៈពេលដែលកំពុងប្រព្រឹត្តបទល្មើសនោះ ជនល្មើស មិនត្រូវបានហាមឃាត់ដោយច្បាប់របស់រដ្ឋនោះទេ ដូច្នេះហើយការចោទប្រកាន់ និងការដាក់ទណ្ឌកម្មជាបន្តបន្ទាប់ប្រឆាំងអ្នកប្រព្រឹត្តដោយផ្អែកតែលើច្បាប់របស់រដ្ឋដែលមានលក្ខណៈមិនច្បាស់លាស់នោះ គឺវាបំពានទៅនឹងគោលការណ៍នីត្យានុកូលភាព")។

(កតិកាសញ្ញាអន្តរជាតិ មាត្រា ១៥(២)) អាច អនុវត្តទៅបាន ប្រសិនបើ អ.វ.ត.ក គឺជាសាលាក្តីអន្តរជាតិមួយ ដូចសាលាក្តី ICTY សាលាក្តី SCSL វាជាហេតុផលមិនត្រឹមត្រូវដែលលើកឡើងថា នួន ជា អាចទំនងមើលឃើញអំពីបទល្មើសព្រហ្មទណ្ឌ ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិនៅក្នុងតុលាការជាតិកម្ពុជា។ និយាយមួយបែបទៀតនោះគឺ វាពិបាកយល់ថាតើបុគ្គលមួយរូបដែលដំណើរការងារនៅក្នុងប្រព័ន្ធទ្វិកនិយមនៅក្នុងប្រទេស ដែលទទួលការការពារតាមគោលការណ៍ *មិនមានបទល្មើស* យ៉ាងរឹងមាំង អាច (ឬ គួរ) យល់ឃើញថា ការការពារបែបនេះនឹងត្រូវបានគេដកហូតចេញវិញនាថ្ងៃណាមួយ ជាពិសេសតាមរយៈដំណើរការដាក់ទណ្ឌកម្មតាមច្បាប់អន្តរជាតិ ដែលអះអាងថាប្រកាន់ខ្ជាប់ និងលើកកំពស់នីតិរដ្ឋនោះ។

៣៧. ប្រសិនបើគោលការណ៍នីត្យានុកូលភាព "សំខាន់បំផុតនោះ គឺជា "គោលការណ៍យុត្តិធម៌មួយ""[១០៦] គោលការណ៍នេះមិនគួរត្រូវបានគេយកមកប្រើប្រាស់ដើម្បីបម្រើការងារសម្រាប់ជារបៀបវារៈនៃរបបអាណានិគមថ្មី ដែលជម្រុញដោយច្បាប់អន្តរជាតិនោះឡើយ ដែលរបៀបវារៈនៃរបបនេះគឺចង់បន្ថយអានុភាពនៃសិទ្ធិរបស់បុគ្គលតាមអានុភាពប្រតិសកម្មនៅក្នុងក្របខណ្ឌជាតិ។ ភាពតានតឹងដែលបានង្កើតឡើងដោយភាពខុសគ្នារវាងវិធីសាស្ត្រជាតិ និងអន្តរជាតិចំពោះគោលការណ៍ *មិនមានបទល្មើស* នោះ ត្រូវតែលុបបំបាត់ចោល អនុលោមតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ។* ក្រៅពីរំលោភសិទ្ធិរបស់ នួន ជា នៅក្នុងរដ្ឋធម្មនុញ្ញ ក្នុងការទទួលបានការចោទប្រកាន់ "ឱ្យស្របតាមច្បាប់" ការអនុញ្ញាតឱ្យគោលការណ៍នីត្យានុកូលភាពអន្តរជាតិមកជាន់លើច្បាប់ជាតិដែលផ្តល់ការការពារជាងនោះ នឹងប៉ះពាល់ដល់អធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

## V. **សន្និដ្ឋាន**

៣៨. ដូចមានហេតុផលលើកឡើងខាងលើ ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា ក.ស.ច.ស មានការភ័ន្តច្រឡំលើអង្គច្បាប់ នៅពេលបញ្ជាក់ថា អ.វ.ត.ក មានយុត្តាធិការលើបទប្រល័យពូជ

---

[106] សេចក្តីសម្រេចលើរឿងក្តី Milutinovic កថាខណ្ឌ ៣៧ (ដកស្រង់ តុលាការយោធាអន្តរជាតិនៅណ្យូរ៉ែមប៊េក) ។

00615586

លេខ/No: D427/3/1

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ-១៤៦)

សាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម និងទម្រង់នៃការទទួលខុសត្រូវដទៃៗទៀត ដែលមិនមានចែងទទួលស្គាល់នៅក្នុងប្រព័ន្ធច្បាប់ជាតិកម្ពុជា នៅចន្លោះពីឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីសូមស្នើឱ្យ អ.ប.ជ ចាត់ទុកជាឥតបានការ និង/ឬកែតម្រូវដីកាដំណោះស្រាយឱ្យបានត្រឹមកម្រិតមួយថា ការទទួលខុសត្រូវរបស់ នួន ជា ដូចដែលបានចោទប្រកាន់ ត្រូវបញ្ជាក់យោង*ដាច់ដោយឡែក* លើបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ នៅក្នុងច្បាប់សារធាតុ ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ យើងខ្ញុំសូមស្នើឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈមួយ ដើម្បីជាផលប្រយោជន៍យុត្តិធម៌ និងតម្លាភាព។

**សហមេធាវីការពារក្តី នួន ជា**

p.p.

**សុន អរុណ**

Michiel PESTMAN **និង** Victor KOPPE